## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារជំនួយសម្រាប់ការអនុវត្ត
# ប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ





## ខែមីនា ឆ្នាំ២០១៥

គាំទ្រដោយអង្គការស៊ីអារអែស
Supported by CRS

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២២ អយក.បឋម

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ

កន្លងមកក្រសួងអប់រំ យុវជន និងកីឡាសង្កេតឃើញថា ការអប់រំកុមារពិការនៅថ្នាក់ក្រោមជាតិបានអនុវត្តល្អប្រសើរ ប៉ុន្តែនៅមានចំណុចខ្វះខាតមួយចំនួនដោយមិនទាន់អនុវត្តឱ្យបានពេញលេញនៅឡើយ។ ដើម្បីជំរុញការអប់រំកុមារពិការឱ្យកាន់តែមានប្រសិទ្ធភាព ឆ្លើយតបទៅនឹងស្មារតីនៃវេទិកាពិភពលោក ស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា គោលនយោបាយស្តីពីសាលាកុមារមេត្រីកម្រិតអប់រំមូលដ្ឋាន ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងច្បាប់ស្តីពីការអប់រំ សំដៅផ្តល់ឱកាស និងជួយកុមារពិការទាំងក្នុងនិងក្រៅសាលា ឱ្យទទួលបានការអប់រំប្រកបដោយសមធម៌ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចខាងក្រោម៖

I.អំពីក្រុមការងារសកម្មភាពកុមារពិការ

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀនត្រូវបង្កើតក្រុមការងារសកម្មភាពកុមារពិការតាមឋានានុក្រមដូចខាងក្រោម៖

១. ក្រុមការងារសកម្មភាពកុមារពិការថ្នាក់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

ក. អំពីសមាសភាព

| | |
|---|---|
| - ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | ប្រធាន |
| - អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តទទួលបន្ទុក | អនុប្រធាន |
| - ប្រធានការិយាល័យបឋមសិក្សា | សមាជិក |
| - ប្រធានការិយាល័យមធ្យមសិក្សាចំណេះទូទៅ | សមាជិក |
| - មន្ត្រីជំនាញអប់រំកុមារតូច | សមាជិក |
| - តំណាងសាលាគរុកោសល្យ និងវិក្រឹតការ (បើមាន) | សមាជិក |
| - តំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ | សមាជិក |
| - តំណាងអ្នកពាក់ព័ន្ធ | សមាជិក |

ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តត្រូវកំណត់សមាសភាពជាក់ស្តែងរបស់ក្រុមការងារនេះ។

**ខ. អំពីភារកិច្ច**

- កំណត់អត្តសញ្ញាណពិការភាព និងសេវាបញ្ជូនកុមារពិការនៅតាមសាលារៀន
- ជំរុញសកម្មភាពការងារអប់រំកុមារពិការថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀនឱ្យមានដំណើរការរលូន
- ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពលើផែនការ និងអនុម័តផែនការអប់រំកុមារពិការ
- ផ្សព្វផ្សាយឯកសារជំនួយសម្រាប់ការអនុវត្តប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ និងគោលការណ៍ណែនាំពាក់ព័ន្ធនឹងការអប់រំកុមារពិការ
- សហការលើការងាររដ្ឋបាល បច្ចេកទេសជាមួយថ្នាក់រាជធានី ខេត្ត និងសម្របសម្រួលជាមួយមន្ទីរ ឬដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារអប់រំកុមារពិការ
- រៀបចំរបាយការណ៍លើការងារអប់រំកុមារពិការទៅថ្នាក់ជាតិ។

២.ក្រុមការងារសកម្មភាពកុមារពិការថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ

**ក. អំពីសមាសភាព**

| | |
|---|---|
| - ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ | ប្រធាន |
| - អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ | អនុប្រធាន |
| - មន្ត្រីជំនាញផ្នែកអប់រំពិសេស/អប់រំកុមារពិការ | សមាជិក |
| - ប្រធានកម្រងសាលារៀន | សមាជិក |
| - តំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ | សមាជិក |
| - តំណាងអ្នកពាក់ព័ន្ធ | សមាជិក |

ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌត្រូវកំណត់សមាសភាពជាក់ស្តែងរបស់ក្រុមការងារនេះ។

**ខ. អំពីភារកិច្ច**

- កំណត់អត្តសញ្ញាណពិការភាព និងសេវាបញ្ជូនកុមារពិការនៅតាមសាលារៀន
- ជំរុញការពិនិត្យសុខភាព និងគាំទ្រសកម្មភាពសិក្សារបស់កុមារពិការនៅតាមសាលារៀន
- ផ្សព្វផ្សាយឯកសារជំនួយសម្រាប់ការអនុវត្តប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ និងគោលការណ៍ណែនាំពាក់ព័ន្ធនឹងការអប់រំកុមារពិការ
- សម្របសម្រួលការងាររដ្ឋបាល បច្ចេកទេស និងរៀបចំផែនការ ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តការងារអប់រំកុមារពិការ
- ធ្វើរបាយការណ៍ និងបូកសរុបលទ្ធផលការងារ។

៣. ក្រុមការងារសកម្មភាពកុមារពិការថ្នាក់សាលារៀន

**ក. អំពីសមាសភាព**

- នាយក ឬនាយិកា ប្រធាន
- នាយករង ឬនាយិការង អនុប្រធាន
- ប្រធានក្រុមបច្ចេកទេស សមាជិក
- តំណាងគណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ សមាជិក
- តំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ សមាជិក
- តំណាងគណៈកម្មការទ្រទ្រង់សាលារៀន សមាជិក
- ប្រធានក្រុមប្រឹក្សាកុមារ សមាជិក
- ជនបង្គោលឃុំ សង្កាត់ស្តារលទ្ធភាពពលកម្មតាមសហគមន៍ សមាជិក
- តំណាងអ្នកពាក់ព័ន្ធ សមាជិក

នាយក ឬនាយិកាសាលាត្រូវកំណត់សមាសភាពជាក់ស្តែងរបស់ក្រុមការងារនេះ។

**ខ. អំពីភារកិច្ច**

- កំណត់អត្តសញ្ញាណពិការភាព និងសេវាបញ្ជូនកុមារពិការនៅតាមសាលារៀនមុនពេលចូលរៀន
- ផ្សព្វផ្សាយព័ត៌មាន និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗពាក់ព័ន្ធការងារអប់រំកុមារពិការ
- ប្រមូលព័ត៌មានពីកុមារពិការ និងតម្រូវការការគាំទ្ររបស់កុមារពិការ
- រៀបចំផែនការអភិវឌ្ឍសាលារៀនដោយបញ្ចូលសកម្មភាពអប់រំបញ្ចូលគ្នា
- ជំរុញសកម្មភាពជួយគាំទ្រកុមារពិការ និងកម្មវិធីអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- គ្រប់គ្រង និងពិនិត្យតាមដានការបង្រៀននិងរៀន ការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ
- អនុវត្តការងាររដ្ឋបាលបច្ចេកទេសនិងផែនការជាមួយគ្រួសហគមន៍ និងផ្នែកពាក់ពន្ធ័នានា
- ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន បុគ្គលិកមណ្ឌលសុខភាព គ្រួសារកុមារពិការដល់ផ្ទះ ដៃគូអភិវឌ្ឍន៍ និងសប្បុរសជន ដើម្បីប្រមូលថវិកាអនុវត្តគម្រោង
- ធ្វើរបាយការណ៍ និងបូកសរុបលទ្ធផល។

## II. អំពីវគ្គបំប៉ន

ក្រុមការងារសកម្មភាពកុមារពិការនៅថ្នាក់មន្ទីរអប់រំ យុវជន និងកីឡាត្រូវសហការជាមួយក្រុមការងារសកម្មភាពកុមារពិការនៅថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំវគ្គបំប៉នស្តីពីឯកសារពាក់ព័ន្ធនឹងការអប់រំកុមារពិការ និងឯកសារជំនួយស្មារតីសម្រាប់កំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ ដល់ក្រុមការងារនៅតាមសាលារៀន។

## III. អំពីការរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅតាមសហគមន៍

១. ក្រុមការងារថ្នាក់មន្ទីរអប់រំ យុវជននិងកីឡារាជធានី ខេត្ត ក្រុមការងារថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ក្រុមការងារថ្នាក់សាលារៀន អង្គការដៃគូពាក់ព័ន្ធនឹងពិការភាព និងអ្នកពាក់ព័ន្ធត្រូវសហការរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅតាមសហគមន៍។

២.ការជ្រើសរើសទីកន្លែង និងពេលវេលា

- ទីកន្លែងគួរធ្វើនៅតាមសាលារៀន ឬវត្តអារាម

- ពេលវេលាគួរជ្រើសរើសយកពេលណាដែលប្រជាជនទំនេរពីការងារដូចជាវិស្សមកាលតូចដោយធ្វើការផ្សព្វផ្សាយតែមួយព្រឹក ឬមួយរសៀល ឬក្នុងទិវាកុមារអន្តរជាតិ០១មិថុនា ឬទិវាជនពិការ ០៣ធ្នូ ឬតាមការជាក់ស្តែងនៃការអនុវត្តគម្រោង។

៣.នាយក ឬនាយិកាសាលាត្រូវរៀបចំគម្រោងសកម្មភាពផ្សព្វផ្សាយដល់សហគមន៍ និងផ្ញើគម្រោងសកម្មភាពនេះទៅតាមឋានានុក្រម។

ការធ្វើគម្រោង និងការរៀបចំសម្ភារសម្រាប់ផ្សព្វផ្សាយមានដូចខាងក្រោមៈ

- រៀបចំគម្រោងផ្សព្វផ្សាយ
- រៀបចំផ្ទាំងរូបភាព បញ្ចាំងទស្សនីយភាពខ្លីៗ ឬបង្ហាញពីសៀវភៅត្លុក
- សម្តែងសិល្បៈដោយសិល្បករ និងសិល្បការិនីពិការ
- រៀបចំសំណួរ ចម្លើយ និងល្បែងផ្សេងៗទៀត
- អាហារសម្រន់ LCD Projector ឧត្បោសនស័ព្ទ Laptop ម៉ាស៊ីនភ្លើង ផ្ទាំងសំពត់ ក្រដាសផ្ទាំងធំ...
- រង្វាន់លើកទឹកចិត្តដល់អ្នកចូលរួមដូចជាប៊ិក សៀវភៅ ឬវត្ថុអនុស្សាវរីយ៍ផ្សេងៗ។

៤. នាយក នាយិកាសាលាត្រូវជូនដំណឹងអំពីសកម្មភាពអប់រំផ្សព្វផ្សាយដល់សហគមន៍ទៅមេភូមិ ដើម្បីជម្រាបបន្តទៅសហគមន៍ មេឃុំ ឬចៅសង្កាត់។

## IV. អំពីការរៀបចំសៀវភៅអាសយដ្ឋានអ្នកផ្តល់សេវា

ក្រុមការងារថ្នាក់រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀនត្រូវធ្វើការទំនាក់ទំនងជាមួយអង្គការដៃគូនៅតាមមូលដ្ឋាន ដើម្បីរកសៀវភៅអាសយដ្ឋានផ្តល់សេវាដែលមានស្រាប់សម្រាប់ប្រើប្រាស់ក្នុងការជួយកុមារពិការ និងបញ្ជូនកុមារពិការទៅរកសេវា។

## V. អំពីការរៀបចំផែនទីខ្នងផ្ទះ

១. ក្រុមការងារសកម្មភាពកុមារពិការថ្នាក់សាលារៀនត្រូវពិនិត្យស្ថិតិកុមារពិការដែលបានចូលរៀននៅក្នុងឆ្នាំសិក្សាចាស់ ដើម្បីរៀបចំអភិវឌ្ឍផែនទីខ្នងផ្ទះនិងពិនិត្យរកកុមារពិការនៅក្នុង និងក្រៅសាលារៀន និងកុមារពិការដែលមានតម្រូវការគាំទ្រ។

២. នាយក នាយិកាសម្របសម្រួលជាមួយគណៈកម្មការទ្រទ្រង់សាលារៀនក្នុងការចុះធ្វើផែនទីខ្នងផ្ទះនៅតាមសាលារៀនគោលដៅ ដោយប្រើប្រាស់កម្រងសំណួរកំណត់អត្តសញ្ញាណកុមារពិការ។

## VI. អំពីការរៀបចំផែនទីសិក្សា

នាយក ឬនាយិកាត្រូវរៀបចំផែនទីសិក្សា និងបញ្ចូលទិន្នន័យព័ត៌មានកុមារពិការដែល

បានពិនិត្យរកពិការភាព និងតម្រូវការគាំទ្រមាន៖

១.ចងក្រងទិន្នន័យដែលប្រមូលបានតាមរយៈការកំណត់អត្តសញ្ញាណមូលដ្ឋាន និងតម្រូវការគាំទ្ររបស់កុមារពិការតាមប្រភេទនីមួយៗ។

២. បញ្ជូនកុមារពិការទៅរកសេវាតាមប្រភេទពិការ រួចផ្តល់ទម្រង់ណែនាំដែលចេញដោយអ្នកផ្តល់សេវាទៅឱ្យគ្រូបង្រៀន ដើម្បីជាជំនួយក្នុងការគាំទ្រកុមារពិការក្នុងថ្នាក់រៀន។

៣.រៀបចំបរិស្ថានសាលារៀន និងថ្នាក់រៀនដើម្បីបង្កលក្ខណៈងាយស្រួលដល់កុមារពិការក្នុងការធ្វើបន្លាស់ទីដូចជា ការសាងសង់ជម្រាល បង្កាន់ដៃបង្គន់អនាម័យ និងសួនកុមារជាដើម។

## VII. អំពីការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ

១. ផ្តល់វគ្គបំប៉នស្តីពីការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការដល់នាយក នាយិកាសាលា និងគ្រូបង្រៀននៅតាមសាលារៀនសាកល្បងណាមួយ។

២. បំប៉នគ្រូដែលបានជ្រើសរើសស្តីពីទម្រង់ណែនាំពីសេវាថែទាំសុខភាព ដើម្បីយល់ដឹងពីរបៀបប្រើប្រាស់ឧបករណ៍ និងព័ត៌មានផ្សេងៗនៅក្នុងទម្រង់ណែនាំដែលចេញដោយកន្លែងផ្តល់សេវា។

## VIII.អំពីការតាមដានគ្រួសារលើការបញ្ជូនកុមារពិការទៅកន្លែងផ្តល់សេវា

១. នាយក នាយិកាសាលាសហការជាមួយគណៈកម្មការទ្រទ្រង់សាលារៀនប្រើប្រាស់បញ្ជីឈ្មោះកុមារពិការដែលបានកំណត់អត្តសញ្ញាណ តារាងកំណត់តម្រូវការ ដើម្បីតាមដានកុមារពិការ និងក្រុមគ្រួសារអំពីការបញ្ជូនកុមារពិការទៅកន្លែងផ្តល់សេវា។

២. នាយក នាយិកាសាលាសហការជាមួយគណៈកម្មការទ្រទ្រង់សាលារៀន ប្រើទម្រង់ណែនាំអំពីសេវាថែទាំសុខភាពដើម្បីផ្តល់ការគាំទ្រ និងពិនិត្យតាមដាន។

## IX. អំពីការពិនិត្យតាមដានការរីកចម្រើនរបស់កុមារពិការ

១. គ្រូបង្រៀនកុមារពិការត្រូវមានផែនការជួយ និងពិនិត្យតាមដានលើសកម្មភាពសិក្សាឥរិយាបថ និងឧបសគ្គនានា ហើយរាយការណ៍ជូននាយក ឬនាយិកាសាលា។

២. ក្រុមការងារបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMT) ត្រូវរៀបចំផែនការចុះពិនិត្យតាមដានការអនុវត្តកម្មវិធីប្រចាំត្រីមាស។

## X. អំពីការអនុវត្តការអប់រំកុមារពិការ

ការអនុវត្តការអប់រំកុមារពិការត្រូវអនុវត្តទៅតាមឯកសារជំនួយសម្រាប់ការអនុវត្តប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ និងឯកសារពាក់ព័ន្ធដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

ទទួលបានសេចក្តីណែនាំនេះ ឯកឧត្តម លោកជំទាវ លោក លោកស្រីអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួងអប់រំ

យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល៖**

- សាលារាជធានី ខេត្ត
- សាលាក្រុង ស្រុក ខណ្ឌ
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
  "ដើម្បីជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ នា.នីតិកម្ម

# អារម្ភកថា

ឯកសារនេះផ្អែកលើបទពិសោធដែលប្រមូលបានពីក្រុមការងារចំនួន០៣ដែលបាន និងកំពុងអនុវត្ត សកម្មភាពសាកល្បងពីវិធីកំណត់អត្តសញ្ញាណនិងសេវាបញ្ជូនកុមារពិការនៅស្រុកសំរោងខេត្តតាកែវ ស្រុកថ្មគោលខេត្តបាត់ដំបង និងក្រុងកំពត ខេត្តកំពត ពីខែមករា ឆ្នាំ២០១០ ដល់ខែធ្នូ ឆ្នាំ២០១១។ អង្គការគាំទ្ររួមមាន៖ អង្គការកាតូលិក សង្គ្រោះ និងអភិវឌ្ឍន៍( CRS) នៅខេត្តតាកែវ អង្គការគ្រួសារថ្មី (KT) នៅខេត្តកំពត និងអង្គការជនពិការអន្តរជាតិបារាំង( HI/F) នៅខេត្តបាត់ដំបង ព្រមទាំងមានកិច្ចសហការ និងការចូលរួមពីក្រុមការងាររបស់នាយកដ្ឋានបឋមសិក្សា ដែលឧបត្ថម្ភដោយកម្មវិធីសកម្មភាពពង្រីកការគាំទ្រវិស័យអប់រំ (ESSSUAP/GPE)។

**សាលារៀនគោលដៅ៖**

- ស្រុកថ្មគោល ខេត្តបាត់ដំបង កម្រងសាលារៀនជ្រៃ ដែលមានសាលាបឋមសិក្សាឃុំជ្រៃ សាលាបឋមសិក្សាហ៊ុនសែនកគោ សាលាបឋមសិក្សាភូមិជ្រៃ សាលាបឋមសិក្សាព្រៃទទឹង សាលាបឋមសិក្សាទួលព្រះខែ និងសាលាបឋមសិក្សាទេព្វិរុណ។ ចំណែកឯ កម្រងសាលារៀនអូរតាគីមាន សាលាបឋមសិក្សាអូរតាគី សាលាបឋមសិក្សាពពាលខែ សាលាបឋមសិក្សាវាលទ្រា សាលាបឋមសិក្សាត្រស់ សាលាបឋមសិក្សាព្រៃទទឹង សាលាបឋមសិក្សាព្រៃដាច់ សាលាបឋមសិក្សាត្រាង សាលាបឋមសិក្សាកកោះ និងសាលាបឋមសិក្សាទួលតាម៉ៅ គាំទ្រដោយអង្គការជនពិការអន្តរជាតិបារាំង។
- ស្រុកសំរោង ខេត្តតាកែវមាន សាលាបឋមសិក្សាព្រៃអារ សាលាបឋមសិក្សាអង្គជុំ សាលាបឋមសិក្សាអង្គសូរឃ្លាំង និងសាលាបឋមសិក្សាតាយឹង គាំទ្រដោយអង្គការកាតូលិកសង្គ្រោះ និងអភិវឌ្ឍន៍។
- ក្រុងកំពត ខេត្តកំពតមាន សាលាបឋមសិក្សាកំពតក្រុង គាំទ្រដោយអង្គការគ្រួសារថ្មី។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថាក្រោយពីទទួលបានឯកសារជំនួយសម្រាប់ការអនុវត្តប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនគ្រប់ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនឹងសហការជាមួយក្រុមការងារមូលដ្ឋានដើម្បីពង្រឹងសមត្ថភាពស្វែងរកឱ្យឃើញកុមារពិការ ហើយកំណត់អត្តសញ្ញាណ និងតម្រូវការរបស់ពួកគេដើម្បីបញ្ជូនទៅរកសេវាសមស្រប និងប្រមូលកុមារទាំងនោះឱ្យបានចូលរៀននៅថ្នាក់អប់រំបញ្ចូលគ្នាប្រកបដោយសមធម៌ជាមិនខាន។

ខ្លឹមសារ ឯកសារនេះបានបង្ហាញពីអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ និង ពិពណ៌នាពីសមាសភាគនៃជំហាននីមួយៗ។ បទពិសោធក្នុងការអនុវត្តន៍បានផ្ដល់ជាឧទាហរណ៍និម្មិតសញ្ញារូបភាព និងអនុសាសន៍ដែលដាក់បញ្ចូលក្នុងផ្នែកផ្សេងៗ ដើម្បីជួយដល់អ្នកអានរកឃើញដោយងាយស្រួល។

| និម្មិតសញ្ញារូបភាព | | | |
|---|---|---|---|
|  |  |  |  |
| ជំហាននៃការអនុវត្ត | អ្នកទទួលខុសត្រូវ | ឧទាហរណ៍នៃការអនុវត្តន៍ | អនុសាសន៍ |

# តារាងមាតិកា


១. អារម្ភកថា

២. បញ្ជីសទ្ទានុក្រមនៃពាក្យបំព្រួញ អក្សរកាត់ និងបច្ចេកសព្ទ

៣. អនុសាសន៍ទូទៅ……………………………………………………………………………..១

៤. លំដាប់អនុសាសន៍លើជំហាននៃការអនុវត្តប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ ……...៣

៥. ជំហានទី១ : ការរៀបចំក្រុមការងារសកម្មភាពកុមារពិការ ……………………………………………..៤

៦. ជំហានទី២ : ការរៀបចំវគ្គបំប៉នសមាជិកក្រុមការងារ ……………………………………………..…...១០

៧. ជំហានទី៣ : ការរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ …………………………..………..១៣

៨. ជំហានទី៤ : ការរៀបចំសៀវភៅអាសយដ្ឋានអ្នកផ្តល់សេវា ……………………………..………...…..១៦

៩. ជំហានទី៥ : ការរៀបចំផែនទីខ្នងផ្ទះ……………………………………………………………...…..១៨

១០. ជំហានទី៦ : ការរៀបចំផែនទីសិក្សា……………………………..……………………………...……២១

១១. ជំហានទី៧ : ការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ……………………………………...……………...២៤

១២.ជំហានទី៨ : ការតាមដានគ្រួសារលើការបញ្ជូនកុមារពិការទៅកន្លែងផ្តល់សេវា២.………………...….. ៧

១៣. ជំហានទី៩ : ការពិនិត្យតាមដានការរីកចម្រើនរបស់សិស្សពិការ………………………………………..៣០

# ឧបសម្ព័ន្ធ

១. ឧបសម្ព័ន្ធ១ក៖ គម្រូនៃកិច្ចព្រមព្រាង អនុសារណៈនៃការយោគយល់

២. ឧបសម្ព័ន្ធ១ខ៖ គម្រូបទដ្ឋានការងារសម្រាប់សមាជិកក្រុមការងារ

៣. ឧបសម្ព័ន្ធ១គ៖ គម្រូផែនការសកម្មភាពការងារ

៤. ឧបសម្ព័ន្ធ២ក៖ របៀបវារៈសិក្ខាសាលាស្ដីអំពីការអប់រំផ្សព្វផ្សាយពីពិការភាព

៥. ឧបសម្ព័ន្ធ២ខ៖ ការសម្ដែងតួពីការប្រើប្រាស់តារាងកំណត់អត្តសញ្ញាណកុមារពិការ

៦. ឧបសម្ព័ន្ធ៤ក៖ ទម្រង់ព័ត៌មានពីសេវារបស់អង្គការក្រៅរដ្ឋាភិបាល

៧. ឧបសម្ព័ន្ធ៥ក៖ ទម្រង់ផែនទីខ្នងផ្ទះ

៨. ឧបសម្ព័ន្ធ៥ខ៖ តារាងកំណត់អត្តសញ្ញាណកុមារពិការ

៩. ឧបសម្ព័ន្ធ៥គ៖ តារាងកុមារពិការដែលត្រូវបញ្ជូនទៅរកការគាំទ្រ

១០. ឧបសម្ព័ន្ធ៦ក៖ ទម្រង់ប្រឹក្សាគ្រូ

១១. ឧបសម្ព័ន្ធ៦ខ៖ ទម្រង់ប្រឹក្សាយោបល់ថៃទាំភ្នែក

១២. ឧបសម្ព័ន្ធ៩ក៖ ស្ថិតិសាលារៀន

១៣. ឧបសម្ព័ន្ធ៩ខ៖ ស្ថិតិស្រុក

១៤. ឧបសម្ព័ន្ធ៩គ៖ ការសង្កេតសាលារៀន

១៥. ឧបសម្ព័ន្ធ៩ឃ៖ ការសង្កេតថ្នាក់រៀន



# អនុសាសន៍ទូទៅ

១. ក្រុមការងារមានតំណាងមកពីនាយកដ្ឋានសុខភាពសិក្សា នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រុមប្រឹក្សាសកម្មភាពជនពិការ និងនាយកដ្ឋានអប់រំកុមារតូច គួរតែបង្កើតឡើងនៅកម្រិតថ្នាក់ជាតិ។ ក្រុមការងារនេះមានការទទួលខុសត្រូវដោយផ្ទាល់ លើការពិនិត្យតាមដានការកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ។ ឧបករណ៍ពិនិត្យតាមដានសមស្រប ត្រូវបានចងក្រងឡើងក្នុងគោលបំណងប្រមូល និងវិភាគទិន្នន័យលើលទ្ធផលសូចនាករជាក់លាក់។វគ្គបំប៉នស្ដីពីការប្រើប្រាស់ឧបករណ៍ពិនិត្យតាមដាន គួរផ្ដល់ដល់សមាជិកទាំងអស់ដើម្បីឱ្យចេះប្រើប្រាស់ យល់ពីខ្លឹមសារ និងធានាបាននូវគុណភាពក្នុងការអនុវត្ត។ ផែនការបំប៉នគួរតែចងក្រងឡើងដើម្បីធានាឱ្យមានការពិនិត្យតាមដានបានទៀងទាត់លើស្រុកគោលដៅដែលបាន និងកំពុងអនុវត្ត។

២.នាយកដ្ឋានសុខភាពសិក្សាត្រូវមានកិច្ចសហការជាមួយនាយកដ្ឋានបឋមសិក្សា នាយកដ្ឋានអប់រំកុមារតូច និងនាយកដ្ឋានមធ្យមសិក្សា ចំណេះទូទៅ ។ តំណាងមកពីក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទានិងក្រសួងសុខាភិបាលត្រូវមានកិច្ចសហការគ្នាផងដែរ។ ពិការភាពជាបញ្ហារួមដែលតម្រូវឱ្យមានកិច្ចសហការក្នុងចំណោម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល។ នាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជននិងកីឡាត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសុខាភិបាល។

៣.ការធានាស្ថេរភាពខ្លឹមសារក្នុងវគ្គបំប៉ន៖ កម្មវិធី និងសម្ភារៈបំប៉ន ចងក្រងដោយក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានប្រើប្រាស់។ គ្រូទាំងអស់នៅក្នុងសាលារៀនសាកល្បង គួរទទួលបាននូវវគ្គបំប៉នកម្រិតមូលដ្ឋានស្ដីពីការអប់រំបញ្ចូលគ្នា ដែលអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា។ **លោកគ្រូ អ្នកគ្រូដែល មានសិស្សខ្សោយក្នុងការមើល បញ្ហាស្ដាប់ ឬសិស្សមានបញ្ហារៀនសូត្រ** នៅក្នុងថ្នាក់រៀនគួរទទួលបាននូវវគ្គបំប៉នជំនាញ ។

៤.មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត គួរជ្រើសរើសយកសាលារៀនចំនួន០២ ទៅ០៤ ក្នុងក្រុង ស្រុក ខណ្ឌដើម្បីអនុវត្តគម្រោងសាកល្បង ។ សាលារៀនសាកល្បងមួយចំនួនតូចនឹងផ្ដល់ឱកាសឱ្យក្រុមការងារអភិវឌ្ឍសមត្ថភាពបន្តិចម្ដងៗ និងធ្វើឱ្យការអនុវត្ត និងការពិនិត្យតាមដានមានភាពងាយស្រួល និងមានប្រសិទ្ធភាព។ ចំនួនសេវាកម្មមានតិចនៅក្នុងតំបន់ ដូច្នេះគួរជ្រើសរើសយកសាលារៀនខ្លះមកធ្វើការសាកល្បង។

៥.ធានានូវសមត្ថភាពដល់សមាជិកក្រុមការងារជាការចាំបាច់ ដែលក្រុមការងារថ្នាក់ក្រុង ស្រុក ខណ្ឌ ទទួលបាននូវវគ្គបំប៉នសមស្របដើម្បីបង្កើនការទទួលខុសត្រូវ។ អង្គការ ដៃគូនានាដែលផ្ដល់ការគាំទ្រ និងក្រសួងអប់រំ យុវជន និងកីឡា តំណាងក្រុមការងារថ្នាក់ជាតិត្រូវរៀបចំផែនការគាំទ្រលើផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស។ ចំពោះការផ្ដល់វគ្គបំប៉ន និងការពិនិត្យតាមដានសកម្មភាពរបស់ក្រុមការងារនេះ គឺតាមរយៈវគ្គសិក្សាសាកល្បង។

៦.ពេលវេលាចុះធ្វើផែនទីខ្នងផ្ទះ និងសហគមន៍ដំបូង មានសារៈសំខាន់ដែលសមាជិកក្រុមការងារចំណាយពេលវេលាជាមួយក្រុមគ្រួសារដើម្បីពន្យល់ពីគោលបំណង និងអត្ថប្រយោជន៍នៃប្រព័ន្ធសេវាបញ្ជូន។ គោលបំណងនៃការចុះធ្វើផែនទីខ្នងផ្ទះដំបូង គឺសិក្សាអំពីបញ្ហារបស់កុមារគ្រប់អាយុចូលរៀន ជួបប្រទះនឹងបញ្ហាប្រឈម។ ដូចនេះក្រុមការងារ គួរប្រើវិធីសន្ទនា ជាជាងត្រូវបំពេញក្នុងទម្រង់សម្ភាសន៍។ ក្រុមគ្រួសារកុមារនឹងប្រើប្រាស់សេវាដែលផ្តល់ឱ្យប្រសិនបើពួកគេយល់ពីគោលបំណង និងអត្ថប្រយោជន៍ទាំងនោះ។ មិនតែប៉ុណ្ណោះពួកគេនឹងទទួលស្គាល់ថាកូនរបស់ពួកគេមានពិការភាព ឬបញ្ហា ប្រសិនបើពួកគេមានអារម្មណ៍ល្អជាមួយនឹងដៃគូសន្ទនា។

# លំដាប់អនុសាសន៍លើជំហាននៃការអនុវត្ត
# ប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ

១ • ការរៀបចំក្រុមការងារសកម្មភាពកុមារពិការ

២ • ការរៀបចំវគ្គបំប៉នសមាជិកក្រុមការងារ

៣ • ការរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅតាមសហគមន៍

៤ • ការរៀបចំសៀវភៅអាសយដ្ឋានអ្នកផ្តល់សេវា

៥ • ការរៀបចំផែនទីខ្នងផ្ទះ

៦ • ការរៀបចំផែនទីសិក្សា

៧ • ការបំប៉នការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ

៨ • ការតាមដានលើការបញ្ជូនកុមារពិការទៅកន្លែងផ្តល់សេវា

៩ • ការពិនិត្យតាមដានការរីកចម្រើនរបស់កុមារពិការ

·

# ជំហានទី១: ការរៀបចំក្រុមការងារសកម្មភាពកុមារពិការ



## អ្នកទទួលខុសត្រូវ

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ខណ្ឌ ស្រុក សាលារៀន។

## អ្នកចូលរួមអនុវត្ត

សហគមន៍ អាជ្ញាធរដែនដី ដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធ (មណ្ឌលសុខភាពឃុំ សង្គមកិច្ច និងកិច្ចការនារីឃុំ)។

## សមាសភាគនៃជំហានទី១

**១-ការបង្កើតក្រុមការងារថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន**

**១.១-ក្រុមការងារថ្នាក់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

-ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ០១រូប

-អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តទទួលបន្ទុកអនុវិស័យទាំងបី ០២ ឬ០៣រូប

-ប្រធាន ឬអនុប្រធានការិយាល័យបឋម មធ្យមសិក្សាចំណេះទូទៅ អប់រំកុមារតូច និងមន្ត្រីជំនាញអប់រំពិសេស តាមតម្រូវការជាក់ស្តែង

- តំណាងសាលាគរុកោសល្យ និងវិក្រឹតការរាជធានី (ខេត្តណាខេត្តដែលគ្មានអនុវត្តតាមជាក់ស្តែង) ០១រូប

-តំណាងមន្ទីរសុខាភិបាលរាជធានី ខេត្ត ០១រូប

-តំណាងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ០១រូប

-តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ០១រូប

-តំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ០១រូប

**១.២-ក្រុមការងារថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ**

-ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ០១រូប

-អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ០២ ឬ០៣រូប

-មន្ត្រីជំនាញផ្នែកអប់រំពិសេស តាមតម្រូវការជាក់ស្តែង

- តំណាងការិយាល័យសុខាភិបាលស្រុកប្រត្តិបត្តិ ឬមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខ០១រូប

- តំណាងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ០១រូប

-ប្រធានកម្រងសាលារៀន តាមតម្រូវការជាក់ស្តែង

-តំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ០១រូប

-តំណាងគណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ ០១រូប

**១.៣-ក្រុមការងារថ្នាក់សាលារៀន**

-នាយកសាលា នាយិកាសាលា ០១រូប

-នាយករង នាយិការង ០១រូប

-ប្រធានក្រុមបច្ចេកទេស ០១រូប

-តំណាងគណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ ០១រូប

-តំណាងមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព ០១រូប

-តំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ០១រូប

-តំណាងគណៈកម្មការទ្រទ្រង់សាលារៀន ០១រូប

-ប្រធានក្រុមប្រឹក្សាកុមារ ០១រូប

-ជនបង្គោលឃុំ សង្កាត់ស្តារលទ្ធភាពពលកម្មតាមសហគមន៍ ០១រូប

**២-អំពីតួនា ទី**

**២.១-ក្រុមការងារថ្នាក់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

-ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធាន

-អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តទទួលបន្ទុកអនុវិស័យទាំងបី អនុប្រធាន

-ប្រធាន ឬអនុប្រធានការិយាល័យបឋម មធ្យមសិក្សាចំណេះទូទៅ អប់រំកុមារតូច និងមន្ត្រីជំនាញអប់រំពិសេស សមាជិក

- តំណាងសាលាគរុកោសល្យ និងវិក្រឹតការរាជធានី (ខេត្ត ករណីខេត្តដែលគ្មានអនុវត្តតាមជាក់ស្តែង) សមាជិក

-តំណាងមន្ទីរសុខាភិបាលរាជធានី ខេត្ត សមាជិក

-តំណាងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត សមាជិក

-តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត សមាជិក

-តំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ សមាជិក

**២.២-ក្រុមការងារថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ**

-ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ប្រធាន

-អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ អនុប្រធាន

-មន្ត្រីជំនាញផ្នែកអប់រំពិសេស សមាជិក

-តំណាងការិយាល័យសុខាភិបាលស្រុកប្រត្តិបត្តិ ឬមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព សមាជិក

- តំណាងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ សមាជិក

-ប្រធានកម្រងសាលារៀន សមាជិក

-តំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ សមាជិក

-តំណាងគណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ សមាជិក

**២.៣-ក្រុមការងារថ្នាក់សាលារៀន**

-នាយកសាលា នាយិកាសាលា ប្រធាន

-នាយករង នាយិការង អនុប្រធាន

-ប្រធានក្រុមបច្ចេកទេស សមាជិក

-តំណាងគណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ សមាជិក

-តំណាងមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព សមាជិក

-តំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ សមាជិក

-តំណាងគណៈកម្មការទ្រទ្រង់សាលារៀន សមាជិក

-ប្រធានក្រុមប្រឹក្សាកុមារ សមាជិក

-ជនបង្គោលឃុំ សង្កាត់ ស្តារលទ្ធភាពពលកម្មតាមសហគមន៍ សមាជិក

**៣-អំពីភារកិច្ច**

**៣.១-ក្រុមការងារថ្នាក់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

-សម្របសម្រួលលើការងាររដ្ឋបាល បច្ចេកទេសជាមួយថ្នាក់រាជធានី ខេត្ត និងសម្របសម្រួលជាមួយមន្ទីរ ឬដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ

-ជានាសកម្មភាពកំណត់អត្តសញ្ញាណពិការភាព និងសេវាបញ្ជូនសិស្សពិការនៅតាមសាលារៀន

-សម្របសម្រួលទៅថ្នាក់ក្រោមដូចជា ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ព្រមទាំងសាលារៀន

-ពិនិត្យឡើងវិញ ឬធ្វើបច្ចុប្បន្នភាពលើផែនការ និងអនុម័តផែនការ

-ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារ។

**៣.២-ក្រុមការងារថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ**

- សម្របសម្រួលលើការងាររដ្ឋបាល បច្ចេកទេស និងផែនការថ្នាក់កម្រងសាលារៀន និងផ្នែកពាក់ព័ន្ធ

-គាំទ្រសកម្មភាពកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនសិស្សពិការនៅតាមសាលារៀន

-ជានាឱ្យមានការពិនិត្យសុខភាព និងគាំទ្រសកម្មភាពសិក្សាដល់សិស្សពិការនៅតាមសាលារៀន

-ផ្សព្វផ្សាយព័ត៌មាន និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ

-លើកផែនការ និងពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារ

-រៀបចំរបាយការណ៍ និងបូកសរុបលទ្ធផល។

**៣.៣-ក្រុមការងារថ្នាក់សាលារៀន**

-សម្របសម្រួលលើការងាររដ្ឋបាល បច្ចេកទេស និងផែនការជាមួយគ្រូ សហគមន៍ និងផ្នែកពាក់ព័ន្ធ

-រៀបចំសកម្មភាពកំណត់អត្តសញ្ញាណពិការភាព និងសេវាបញ្ជូនសិស្សពិការនៅតាមសាលារៀនមុនពេលចុះឈ្មោះចូលរៀន

- ផ្សព្វផ្សាយព័ត៌មាន និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ

-ប្រមូលព័ត៌មានពីកុមារពិការ និងតម្រូវការគាំទ្រកុមារពិការ

-បញ្ចូលសកម្មភាពអប់រំបញ្ចូលគ្នាទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់

-គ្រប់គ្រង និងពិនិត្យតាមដានការបង្រៀន និងរៀនពីការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ
-បញ្ចូលផែនការជួយគាំទ្រសិស្សពិការ និងកម្មវិធីអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ ទៅក្នុង ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់
-ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន បុគ្គលិកមណ្ឌលសុខភាព និងគ្រួសារកុមារពិការដល់ផ្ទះ
-ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ សប្បុរសជនដើម្បីប្រមូលថវិកាអនុវត្តគម្រោង
-រៀបចំរបាយការណ៍ និងបូកសរុបលទ្ធផល។

**៤-ការជ្រើសរើសគោលដៅ**

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តការិយាល័យអប់រំ យុវជន និងកីឡាក្រុង ខណ្ឌ ស្រុក សហការជ្រើសរើសយកសាលារៀនគោលដៅទៅតាមស្ថានភាពជាក់ស្តែង។

**៥.ឧទាហរណ៍នៃការអនុវត្ត និងអនុសាសន៍**



## ឧទាហរណ៍នៃការអនុវត្ត

### ទស្សនកិច្ចសិក្សា

ក្រុមការងាររបស់អង្គការCRS ក្នុងស្រុកសំរោង ខេត្តតាកែវបានរៀបចំទស្សនកិច្ចសិក្សា តាមស្រុកនិងកម្មវិធីដទៃទៀតដោយរៀនអំពីការអនុវត្តការអប់រំបញ្ចូល គ្នានៅកម្ពុជា និងផ្លាស់ប្តូរបទពិសោធពីការអប់រំបញ្ចូលគ្នាទៅវិញទៅមក។ ក្រុមការងារបានធ្វើទស្សនកិច្ចសិក្សានៅអង្គការមនុស្សលោកថ្មី(NH) នៅខេត្តកំពង់ឆ្នាំង និងអង្គការសេវាកម្មអភិវឌ្ឍន៍ជនពិការ (DDSP) នៅខេត្តពោធិសាត់។ ការអនុវត្តល្អមួយចំនួនដែលក្រុមការងារសង្កេតឃើញត្រូវបានពាំនាំមកជាមួយទុកជាបទពិសោធផ្ទាល់ខ្លួនៈ

-រៀបចំសកម្មភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការកុមារពិការ
-ផ្តល់វគ្គបំប៉នដល់ក្រុមការងារដើម្បីពង្រឹងចំណេះដឹង
-ផ្តល់វគ្គបំប៉នពីវិធីសាស្ត្រល្អដល់គ្រូដែលបង្រៀនកុមារពិការប្រកបដោយគុណភាព
-ពិនិត្យតាមដាន និងឆ្លុះបញ្ចាំងពីភាពរីកចម្រើននៃការអនុវត្ត



# ឧទាហរណ៍នៃការអនុវត្ត

## អនុគណៈកម្មការទទួលខុសត្រូវដោយឡែកពីគ្នា

នៅស្រុកថ្មគោល ខេត្តបាត់ដំបង ក្រុមការងារតម្រូវឱ្យមានអនុគណៈកម្មការ០២ គឺ អនុគណៈកម្មការទទួលបន្ទុកការងារអប់រំ និងអនុគណៈកម្មការទទួលបន្ទុកការងារសហគមន៍។

**ទំនួលខុសត្រូវដោយឡែករបស់អនុគណៈកម្មការទទួលបន្ទុកការងារអប់រំរួមមាន៖**

១.បន្តការគាំទ្រដោយផ្ទាល់ដល់សាលារៀន និងគ្រូដែលបង្រៀនសិស្សពិការជាទៀងទាត់

២ .អនុវត្ត និងតាមដានលើទម្រង់ប្រឹក្សាដើម្បីពិនិត្យលើភាពរីកចម្រើនរបស់សិស្សពិការ និងគុណភាពអប់រំរបស់ពួកគេ

៣ .អប់រំផ្សព្វផ្សាយនៅក្នុងសាលា( ឧទាហរណ៍នៅពេលចាប់ផ្តើមប្រារព្ធទិវាបើកបវេសនកាល ទិវាជនពិការអន្តរជាតិ ទិវាកុមារអន្តរជាតិ)

៤ . រៀបចំដំណើរទស្សនៈកិច្ចសិក្សាសម្រាប់បុគ្គលិកសិក្សានៅស្រុកគោលដៅផ្សេងទៀត

៥ . រាយការណ៍ពីទិន្នន័យកុមារពិការដែលអវត្តមាន ឬបោះបង់ការសិក្សាឱ្យបានទៀងទាត់ជូនដល់អនុគណៈកម្មការទទួលបន្ទុកការងារអប់រំ

**ទំនួលខុសត្រូវដោយឡែករបស់អនុគណៈកម្មការទទួលបន្ទុកការងារសហគមន៍រួមមាន៖**

១. អប់រំផ្សព្វផ្សាយនៅសហគមន៍

២ . ធ្វើការពិនិត្យតាមដានជាមួយក្រុមគ្រួសារជាពិសេសសម្រាប់កុមារដែលអវត្តមាន ឬបោះបង់ការសិក្សាជាទៀងទាត់

៣ . ផ្តល់ការគាំទ្រដល់ក្រុមគ្រួសារពីបំណិនជីវិតសម្រាប់យុវវ័យពិការ

៤ . ធ្វើការបញ្ជូនកុមារពិការទៅរកសេវាវេជ្ជសាស្ត្រនិងសង្គម

**គុណប្រយោជន៍ដែលមានអនុគណៈកម្មការទាំងពីរ៖**

១.មានភាពច្បាស់លាស់លើតួនាទី និងទំនួលខុសត្រូវនៅពេលមានអនុគណៈកម្មការពីរ អនុគណៈកម្មការនីមួយៗយល់ពីទំនួលខុសត្រូវកាន់តែប្រសើរឡើង។ សមាជិកនៃអនុគណៈកម្មការនីមួយៗអាចមានឆន្ទៈកាន់តែខ្លាំងលើសកម្មភាពដែលត្រូវធ្វើបើសិនជាពួកគេយល់ច្បាស់ពីទំនួលខុសត្រូវ

២ .អនុគណៈកម្មការទទួលបន្ទុកការងារអប់រំធ្វើការងារក្នុងសាលារៀន និងមានទំនួលខុសត្រូវលើគ្រប់សកម្មភាពទាក់ទងនឹងការងារអប់រំទាំងអស់ ចំណែកឯអនុគណៈកម្មការទទួលបន្ទុកការងារសហគមន៍មានទំនួលខុសត្រូវលើគ្រប់សកម្មភាពទាក់ទងនឹងការងារសហគមន៍។ អនុគណៈកម្មការទាំងពីរធ្វើការងារជាមួយគ្នាក្នុងករណីការងារអប់រំ និងសហគមន៍មានទំនាក់ទងមិនអាចកាត់ផ្តាច់ចេញពីគ្នាបាន។

## អនុសាសន៍

១.បញ្ជាក់ពីការទទួលខុសត្រូវ និងការប្តេជ្ញាចិត្តរបស់សមាជិក ។ សមាសភាពសមាជិកមួយចំនួននៃក្រុមការងារអាចមានអនិយ័តភាពដោយសារតែពួកគេមានការងារច្រើនត្រូវធ្វើ ។

២.នាយកដ្ឋានសុខភាពសិក្សាគួរតែដឹកនាំការអនុវត្តដោយមានកិច្ចសហការជាមួយនាយកដ្ឋានបឋមសិក្សា ។

៣.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសុខាភិបាលគួរតែមានកិច្ចសហការ និងផ្តល់សេវា។

៤.គណៈកម្មការទ្រទ្រង់សាលារៀនចូលរួមជាសមាជិកក្នុងក្រុមការងារ។

៥.ធានានិរន្តរភាពលើថវិកាសម្រាប់ក្រុមការងារក្នុងការអនុវត្តសកម្មភាព។

៦.ការអនុវត្តការអប់រំបញ្ចូលគ្នាត្រូវចាប់ផ្តើមជាដំណាក់ៗ។ ស្រុកនីមួយៗអាចមានការប្រឈមផ្សេងៗគ្នានិងអាចចំណាយពេលវេលាច្រើនក្នុងការអនុវត្ត ដូចនេះគួរ មានការ អំណត់អត់ធន់។

៧.ទស្សនកិច្ចសិក្សាសម្រាប់ក្រុមការងារ ជាអនុសាសន៍សំខាន់មួយ។ ទស្សនៈកិច្ចសិក្សាអាចធ្វើឡើងក្នុងប្រទេស ឬប្រសិនបើមានថវិកាគ្រប់គ្រាន់នឹងមានទស្សនៈកិច្ចសិក្សានៅក្រៅប្រទេសព្រោះគម្រោង សាកល្បងចាំបាច់ត្រូវរៀនសូត្រ ឬដកស្រង់បទពិសោធពីស្ថាប័ន និង ប្រទេសដទៃ។

# ជំហានទី២ : ការរៀបចំវគ្គបំប៉នសមាជិកក្រុមការងារ

**អ្នកទទួលខុសត្រូវ**

នាយកដ្ឋានបឋមសិក្សា ឬ នាយកដ្ឋានអប់រំកុមារតូច ឬ នាយកដ្ឋានមធ្យមសិក្សា

**អ្នកចូលរួមអនុវត្ត**

នាយកដ្ឋានពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍

**សមាសភាគនៃជំហានទី២**

**១.ផ្តល់វគ្គបំប៉នស្តីពីការយល់ដឹងពីពិការភាព**

ផ្តល់វគ្គបំប៉នដល់សមាជិកក្រុមការងារស្តីពីពិការភាព ការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ និងសិទ្ធិទទួលបានការអប់រំ និងឯកសារជំនួយស្មារតីសម្រាប់កំណត់អត្តសញ្ញាណកុមារពិការ។

**២.ផ្តល់វគ្គបំប៉នពីការរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅសហគមន៍**

ផ្តល់វគ្គបំប៉នពីការរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅសហគមន៍ ដោយប្រើប្រាស់សម្ភារៈដូចជា៖ផ្ទាំងរូបភាព ទស្សនីយភាពខ្លីៗ ឬសៀវភៅត្លុក (ឧបករណ៍ពាក់ព័ន្ធដែលអាចរកបាន) សំណួរចម្លើយ ល្បែង ផ្សេងៗ...ការបង្ហាញបទពិសោធដោយវាគ្មិនជាជនពិការ ឬក្រុមគ្រួសាររបស់ជនពិការ។

**៣.ឧទាហរណ៍នៃការអនុវត្ត និងអនុសាសន៍**

## ឧទាហរណ៍នៃការអនុវត្ត

ក្នុងស្រុកសំរោង ខេត្តតាកែវ ដោយមានការគាំទ្រពីអង្គការកាតូលិក សង្គ្រោះ និងអភិវឌ្ឍន៍ (CRS) ជាអង្គការមិនមែនរដ្ឋាភិបាល បានអញ្ជើញលោកស្រី **មាស សុខុម** ជាម្តាយយុវជនមានបញ្ហាបញ្ញាម្នាក់ឱ្យនិយាយអំពីបទពិសោធក្នុងការខំប្រឹងប្រែងបីបាច់ថែរក្សាកូនរបស់គាត់ នៅពេលគ្មានសេវាព្យាបាល។សាច់រឿងរបស់គាត់បានជួយដល់ក្រុមការងារឱ្យយល់ពីសារៈសំខាន់នៃការជួយរបស់ក្រុមគ្រួសារតាមរយៈការផ្តល់ការគាំទ្រក្នុងការទទួលយកសេវាបញ្ជូន ឬការបញ្ជូនកូនពិការរបស់ពួកគាត់ទៅសាលារៀន។



វគ្គបណ្តុះបណ្តាលនេះអាចផ្តល់ឱ្យបន្ទាប់ពីសកម្មភាពអប់រំផ្សព្វផ្សាយនៅសហគមន៍សម្រាប់លើកកម្ពស់ការយល់ដឹង និងការចងក្រងសៀវភៅអាសយដ្ឋានអ្នកផ្តល់សេវា។ វគ្គបំប៉ននេះត្រូវបានរៀបចំឡើងមុនពេលចុះធ្វើផែនទីខ្នងផ្ទះ និងផែនទីសិក្សា។ សៀវភៅវាយឈ្មោះអាសយដ្ឋានអ្នកផ្តល់សេវាជាប្រភពដ៏សំខាន់មួយក្នុងពេលបំប៉ន។

| **ការផ្តល់វគ្គបំប៉នដល់ក្រុមការងារ** | | | |
|---|---|---|---|
| ល.រ | **ឈ្មោះវគ្គបំប៉ន** | **គ្រូឧទ្ទេស** | **រយៈពេល** |
| ១ | ការអប់រំផ្សព្វផ្សាយពីពិការភាព | នា.បឋមសិក្សា<br>នា.អប់រំកុមារតូច<br>នាយកដ្ឋានមធ្យមសិក្សា<br>និងអង្គការដៃគូ | ០៣ថ្ងៃ |
| ២ | ការរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅសហគមន៍ | នា.បឋមសិក្សា<br>នា.អប់រំកុមារតូច<br>នាយកដ្ឋានមធ្យមសិក្សា<br>និងអង្គការដៃគូ | ០១ថ្ងៃ |
| ៣ | ការប្រើប្រាស់ឯកសារជំនួយស្មារតីសម្រាប់កំណត់អត្តសញ្ញាណកុមារពិការ | នា.បឋមសិក្សា<br>នា.អប់រំកុមារតូច<br>នាយកដ្ឋានមធ្យមសិក្សា<br>និងអង្គការដៃគូ | ០២ថ្ងៃ |
| ៤ | ការអប់រំបញ្ចូលគ្នា និងសិទ្ធិកុមារទទួលបានការអប់រំ<br>(ទៅកាន់សមាជិកសហគមន៍) | នា.បឋមសិក្សា<br>នា.អប់រំកុមារតូច<br>នាយកដ្ឋានមធ្យមសិក្សា<br>និងអង្គការដៃគូ | ០៣ថ្ងៃ |
| ៥ | ការគ្រប់គ្រងការអប់រំបញ្ចូលគ្នា | នា.បឋមសិក្សា<br>នា.អប់រំកុមារតូច<br>នាយកដ្ឋានមធ្យមសិក្សា<br>និងអង្គការដៃគូ | ០៥ថ្ងៃ |

កូនសៀវភៅស្តីពីវគ្គបំប៉នក្នុងការប្រើប្រាស់សៀវភៅត្លុកដើម្បីអប់រំផ្សព្វផ្សាយពីពិការភាព និងសម្ភារៈដទៃទៀត រាប់បញ្ចូលទាំងសេចក្តីណែនាំពីការប្រើប្រាស់ផ្ទាំងរូបភាព សៀវភៅ ត្លុក និងផ្ទាំងទស្សនីយភាព ទូរទស្សន៍ជាឧបករណ៍អប់រំផ្សព្វផ្សាយដែលអាចប្រើប្រាស់ និងរកបាន ពីអង្គការជនពិការអន្តរជាតិបារាំង ឬ**ការិយាល័យអប់រំ យុវជន និងកីឡា ស្រុកថ្មគោល។**

ព័ត៌មានបន្ថែមទៀតពីវគ្គបំប៉នស្តីពី ការគ្រប់គ្រងការអប់រំបញ្ចូលគ្នា គឺអាចរកបាន ពី**អង្គការកាតូលិក សង្គ្រោះ និងអភិវឌ្ឍន៍** ដែលមានទីស្នាក់ការការិយាល័យនៅផ្ទះលេខ១៤ ផ្លូវ២៧៨ សង្កាត់បឹងកេងកង១ ភ្នំពេញ ។ ទូរស័ព្ទ៖ **០២៣ ២១១ ១៦៥ និង មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ**

CATHOLIC RELIEF SERVICES



## អនុសាសន៍

១.ប្រើប្រាស់កម្មវិធីសិក្សា និងសម្ភារៈចងក្រងដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធានាស្តេរភាពខ្លឹមសារក្នុងវគ្គបំប៉ន។

២.រៀបចំវគ្គបំប៉នពីការប្រើប្រាស់តារាងកំណត់អត្តសញ្ញាណកុមារពិការ មុននឹងរៀបចំផែនទីខ្នងផ្ទះ និងផែនទីសិក្សា។

៣.វាជាការសំខាន់ណាស់ ដើម្បីធានាថាសមត្ថភាពរបស់សមាជិកក្រុមការងារត្រូវបានពង្រឹងតាមរយៈលទ្ធផលវគ្គបំប៉ន។ ព្រោះថាក្រុមការងារនឹងរៀបចំវគ្គបំប៉នដោយខ្លួនគេផ្ទាល់ ហើយពិតជាមានលទ្ធភាពធ្វើបានល្អ។



# ជំហានទី៣:ការរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅតាមសហគមន៍



**អ្នកទទួលខុសត្រូវ**

ក្រុមការងារថ្នាក់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តក្រុង ស្រុក ខណ្ឌ សាលារៀន គណៈកម្មការទ្រទ្រង់សាលារៀន។

**អ្នកចូលរួមអនុវត្ត**

សហគមន៍ អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍ ។

**សមាសភាគនៃជំហានទី៣**

**១.ការជ្រើសរើសទីកន្លែង និងពេលវេលា**

-ទីកន្លែងគួរធ្វើនៅតាមសាលារៀន ឬវត្តអារាម។

-ពេលវេលាគួរជ្រើសយកពេលណាដែលប្រជាជនទំនេរពីការងារដូចជា៖ ពេលវិស្សមកាលតូច ឬទិវាកុមារអន្តរជាតិ១មិថុនា ឬទិវាជនពិការពាធ្ល ត្រឹមតែមួយរសៀល ឬមួយព្រឹកតាមការដាក់ស្តែងនៃការអនុវត្តគម្រោង។

**២.ការធ្វើគម្រោងសម្រាប់សកម្មភាពផ្សព្វផ្សាយ និងរៀបចំសម្ភារៈ**

***ការធ្វើគម្រោង**

-រៀបចំផ្ទាំងរូបភាព បញ្ចាំងទស្សនីយភាពខ្លីៗ ឬបង្ហាញសៀវភៅត្លុក

-សម្តែងសិល្បៈដោយសិល្បករ និងសិល្បការិនីពិការ

-រៀបចំសំណួរចម្លើយ និងល្បែងផ្សេងៗ

***ការរៀបចំសម្ភារចាំបាច់**

-អាហារសម្រន់ Laptop, LCD Projector ឧគ្ល្បាសនស័ព្ទ ផ្ទាំងសំពត់ ក្រដាសផ្ទាំងធំ ម៉ាស៊ីនភ្លើង

-រង្វាន់លើកទឹកចិត្តដល់អ្នកចូលរួមដូចជា៖ ប៊ិក សៀវភៅ ឬវត្ថុអនុស្សាវរីយ៍

**៣.ការជូនដំណឹងអំពីសកម្មភាពអប់រំផ្សព្វផ្សាយដល់សហគមន៍**

នាយកសាលាជូនដំណឹងទៅប្រធានភូមិដើម្បីជម្រាបបន្តទៅសហគមន៍ មេឃុំ ឬចៅសង្កាត់ ។

## ៤.២ឧទាហរណ៍នៃការអនុវត្ត និងអនុសាសន៍



### ឧទាហរណ៍នៃការអនុវត្ត

នៅស្រុកសំរោង ខេត្តតាកែវ ក្រុមការងារដែលមានការគាំទ្រពីអង្គការកាតូលិកសង្គ្រោះ និងអភិវឌ្ឍន៍ បានរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅសហគមន៍ ក្នុងវត្តមួយកាលពីល្ងាចថ្ងៃសៅរ៍ ។ នាយកសាលា និងប្រធានភូមិត្រូវអញ្ជើញដោយផ្ទាល់មាត់ទៅកាន់សហគមន៍ និង លិខិតអញ្ជើញទៅកាន់ប្រធានភូមិ និងមេឃុំ។ សកម្មភាពអប់រំផ្សព្វផ្សាយនេះមានវត្តមានមាតា បិតារបស់កុមារពិការ ដោយបាននាំកូនពិការរបស់គាត់មកជាមួយ។ ក្រុមការងារបានរៀបចំម៉ាស៊ីនភ្លើង និងក្បាលបញ្ចាំងស្លាយ ដោយបង្ហាញពីទស្សនីយភាពទូរទស្សន៍ខ្លីព្រមទាំងផ្តល់ អាហារសម្រន់ផងដែរ។ តំណាងមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវបានពន្យល់ពីបំណងនៃគម្រោងសាកល្បងនេះ។ សកម្មភាពអប់រំផ្សព្វផ្សាយនេះមានការសម្តែងសិល្បៈរបស់អង្គការគ្រួសារថ្មី ដោយសិស្សមានបញ្ហាស្តាប់ សម្តែងកាយសម្ព័ន្ធខណៈពេលដែលសិស្សមានបញ្ហាមើលជួយស្រែកបន្ទរតាមចម្រៀង។







## អនុសាសន៍

១. ជានាថាមានការគាំទ្រថវិកាគ្រប់គ្រាន់ សម្រាប់រៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅសហគមន៍។ ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់សម្ភារៈអប់រំផ្សព្វផ្សាយ (ផ្ទាំងរូបភាព វីឌីអូខ្លី និងខ្សែអាត់វិទ្យុខ្លី) ដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត សម្រាប់ការអប់រំផ្សព្វផ្សាយ។ ក្រុមការងារគួរលៃថវិកាសម្រាប់ថ្លៃប្រើប្រាស់ក្បាលបញ្ចាំងស្លាយ ក្បាលបញ្ចាំងវីឌីអូ និងឧបករណ៍ឧគ្ឃោសនស័ព្ទ។

២. ត្រូវរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយតាមវត្តនិងផ្តល់អាហារសម្រន់ដែលធ្វើឱ្យមានការចូលរួមពីសហគមន៍កាន់តែច្រើន ហើយត្រូវជ្រើសរើសពេលល្អដូចជារសៀលថ្ងៃសៅរ៍ដែលមនុស្សភាគច្រើនចង់ចូលរួម។

៣. ជានាថាអ្នកធ្វើការអប់រំផ្សព្វផ្សាយមានសមត្ថភាព និងការយល់ដឹងខ្ពស់ ព្រោះការសម្របសម្រួលត្រូវសួរ និងឆ្លើយសំណួរក្នុងការអប់រំផ្សព្វផ្សាយដល់អ្នកចូលរួម។

# ជំហានទី៤ :ការរៀបចំសៀវភៅអាសយដ្ឋានអ្នកផ្តល់សេវា

## អ្នកទទួលខុសត្រូវ

ក្រសួងអប់រំ យុវជន និងកីឡា

## អ្នកចូលរួមអនុវត្ត

នាយកដ្ឋានពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍

## សមាសភាគនៃជំហានទី៤

### ១.ប្រើសៀវភៅអាសយដ្ឋានដែលមានស្រាប់ ដើម្បីឱ្យដឹងពីធនធានអាចប្រើប្រាស់បាន

Sharing Experience for Adapted Development (SEAD) មានសៀវភៅអាសយដ្ឋានក្នុងការផ្តល់ទំនាក់ទំនង និងផ្តល់ព័ត៌មានពាក់ព័ន្ធអំពីសេវាកម្មសង្គម និងវេជ្ជសាស្ត្រដែលធ្វើសហប្រតិបត្តការក្នុងប្រទេស។ សៀវភៅអាសយដ្ឋានសេវាកម្មនេះអាចប្រើប្រាស់ ដោយមានអង្គការបានចែករំលែកបទពិសោធន៍ ដើម្បីសម្របសម្រួលលើការអភិវឌ្ឍន៍(SEAD) ច្បាប់ចម្លងជាភីឌីអេហ្វ(pdf) អាចបោះពុម្ពជាភាសាខ្មែរនិងភាសាអង់គ្លេសខ្លះយកបានតាមគេហទំព័រនេះ៖http://sead-cambodia.org/index.php?option=com_content&view=article&id=102:directory-online&catid=37:projects&Itemid=180

អង្គការជនពិការអន្តរជាតិបានចងក្រងបញ្ជីធនធានសម្រាប់ខេត្តបាត់ដំបង កំពង់ ចាម និង ភ្នំពេញ។ សៀវភៅអាសយដ្ឋាននេះអាចប្រើប្រាស់បាននៅការិយាល័យរបស់អង្គការជនពិការអន្តរជាតិបារាំងនៅខេត្តបាត់ដំបង (លេខទូរស័ព្ទ:០៥៣ ៩៥២ ៥៥០)។ អ៊ីម៉ែល: pm-iep@hicambodia.org MEDICAM មានបញ្ជីសេវាកម្មផងដែរ ដែលអាចមានដំណើរការតាមLinkខាងក្រោមនេះ៖ http://www.medicam-cambodia.org/hsi/health_mapping/GisSrch_org.asp

អង្គការកាតូលិក សង្គ្រោះ និងអភិវឌ្ឍន៍ ក៏បានបង្កើតសៀវភៅអាសយដ្ឋានក្នុងការផ្តល់ទំនាក់ទំនង និងផ្តល់ព័ត៌មានពាក់ព័ន្ធអំពីសេវាកម្មសង្គម ស្តារលទ្ធភាពពលកម្ម និងវេជ្ជសាស្ត្រ នៅខេត្តតាកែវ កំពង់ស្ពឺ កណ្តាល និងភ្នំពេញ ។ លើសពីនេះទៅទៀតក្រសួងអប់រំ យុវជន និងកីឡា កំពុងដំណើរការក្នុងការចងក្រងសៀវភៅអាសយដ្ឋានរបស់អង្គការ។

### ២.ការបង្កើតសៀវភៅអាសយដ្ឋានអ្នកផ្តល់សេវាចំពោះមូលដ្ឋានដែលពុំទាន់មាន

ប្រើទម្រង់ភ្ជាប់ជាមួយដែលចងក្រងដោយអង្គការជនពិការអន្តរជាតិបារាំង ដើម្បីឱ្យព័ត៌មានដូចគ្នាគ្រប់ភ្នាក់ងារទាំងអស់។ (សូមមើលឧបសម្ព័ន្ធ៤ក)

ព័ត៌មានអាចប្រមូលបានដោយប្រើវិធីដូចជា៖

- ផ្ញើអ៊ីម៉ែលទៅកាន់អង្គការ ហើយអង្គការត្រូវផ្ញើត្រឡប់មកវិញ
- ណាត់ជួបប្រជុំជាមួយអង្គការ ដើម្បីធ្វើការបំពេញទម្រង់ជាមួយគ្នា
- ចងក្រងទៅជាកូនសៀវភៅ និងចែកចាយដល់សមាជិកក្រុមការងារ និងអង្គការពាក់ព័ន្ធ

-អង្គការពាក់ព័ន្ធត្រូវសហការអាចផ្តល់ថវិកា និងអនុវត្តការងារទំនាក់ទំនងនេះដោយប្រមូលព័ត៌មាន និងបោះពុម្ពជាសៀវភៅអាសយដ្ឋានអ្នកផ្តល់សេវា។



# អនុសាសន៍

១.បើសិនជាគ្មានព័ត៌មានអំពីសេវាកម្មអាចប្រើប្រាស់បាននៅក្នុងខេត្ត ជំហាននេះគួរតែបង្កើតឡើងជាដំបូង ដើម្បីធានាថាព័ត៌មានអាចប្រើប្រាស់បាននៅពេលធ្វើផែនទីខ្នងផ្ទះ ផែនទីសិក្សា។

២.សេវាករខ្លះអាចត្រូវការពេលវេលាបន្ថែមទៀត ដើម្បីតាមដានក្នុងការផ្តល់ព័ត៌មានចាំបាច់។

៣.ត្រូវធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលកំណត់ណាមួយ (អាច៣ឆ្នាំម្តង ) ដើម្បីបត់បែនតាមការប្រែប្រួល ជាក់ស្តែងនៃអាសយដ្ឋានអ្នកផ្តល់សេវា។

.

# ជំហានទី៥ : ការរៀបចំផែនទីខ្នងផ្ទះ



**អ្នកទទួលខុសត្រូវ**

ការិយាល័យអប់រំ យុវជន និង កីឡាក្រុង ខណ្ឌ ស្រុក សាលារៀន

**អ្នកចូលរួមអនុវត្ត**

សហគមន៍ អាជ្ញាធរដែនដី និង ដៃគូអភិវឌ្ឍន៍

**សមាសភាគនៃជំហានទី៥**

**១.សម្របសម្រួលជាមួយគណៈកម្មការទ្រទ្រង់សាលារៀនក្នុងការចុះធ្វើផែនទីខ្នងផ្ទះ**

ស្វែងយល់ពីផែនការរបស់គណៈកម្មការទ្រទ្រង់សាលារៀន ក្នុងការចុះធ្វើផែនទីខ្នងផ្ទះនៅសាលា រៀនដែលបានជ្រើសរើស សម្រាប់ធ្វើយុទ្ធនាការចុះឈ្មោះចូលរៀន ។ សម្របសម្រួលនៅពេលតែមួយជាមួយគណៈកម្មការទ្រទ្រង់សាលារៀន ក្នុងការចុះធ្វើផែនទីខ្នងផ្ទះសម្រាប់កុមារពិការ។ ពេលវេលាល្អក្នុងការរៀបចំផែនទីខ្នងផ្ទះគឺក្នុងអំឡុងចុងសប្តាហ៍ ស្របពេលដែលក្រុមគ្រួសារភាគច្រើនទំនេរពីការងារ។ (សូមមើល ឧបសម្ព័ន្ធ ៥ក ទម្រង់ផែនទីខ្នងផ្ទះ)

**២.ធានាថាសមាជិកក្រុមការងារទាំងអស់ទទួលបានវគ្គបំប៉នស្តីពី ការប្រើប្រាស់ឯកសារជំនួយស្មារតីសម្រាប់កំណត់អត្តសញ្ញាណកុមារពិការ**

សមាជិកក្រុមការងារមូលដ្ឋាន ត្រូវទទួលបានវគ្គបំប៉នស្តីពីការប្រើប្រាស់តារាងកំណត់អត្តសញ្ញាណ និងការគាំទ្រចាំបាច់ (សូមមើលឧបសម្ព័ន្ធ៥ខ៖ តារាងកំណត់អត្តសញ្ញាណកុមារពិការ និងឧបសម្ព័ន្ធ៥គ៖ តារាងគាំទ្រចាំបាច់)។ ការសម្តែងតួអាចប្រើប្រាស់សម្រាប់វគ្គបំប៉ននេះ។ (សូមមើលឧបសម្ព័ន្ធ២ខ)

**៣.រៀបចំផែនការប្រជុំមុនពេលចុះធ្វើផែនទីខ្នងផ្ទះ**

-បែងចែកសមាជិកក្រុមការងារជាក្រុមតូចដើម្បីចុះសម្ភាសន៍ក្រុមគ្រួសារដែលនៅក្នុងផែនទីខ្នងផ្ទះដែលបានជ្រើសរើស។

-ស្វែងយល់ឯកសារជំនួយស្មារតីសម្រាប់កំណត់អត្តសញ្ញាណកុមារពិការ បញ្ជីការគាំទ្រចាំបាច់ និងកូនសៀវភៅធនធានដែលអាចប្រើប្រាស់គ្រប់ៗគ្នា។

-ព្រាងផែនទីខ្នងផ្ទះ។

**៤.រៀបចំការប្រជុំជាបន្តបន្ទាប់ ដើម្បីពិភាក្សាអំពីលទ្ធផលនៃការចុះធ្វើផែនទីខ្នងផ្ទះ**

វិភាគទិន្នន័យព័ត៌មានដែលប្រមូលបានតាមរយៈការកំណត់អត្តសញ្ញាណជាមូលដ្ឋាន និងតម្រូវការគាំទ្រដោយបង្កើតតារាងប្រភេទពិការ និងការគាំទ្រដែលកំណត់បានតាមតម្រូវការរបស់កុមារពិការ។ ក្នុងពេលធ្វើការវិភាគ និងការចង់ដឹងពីប្រភេទពិការមិនសូវសំខាន់នោះទេ អ្វីដែលសំខាន់នោះគឺចង់ដឹងពីតម្រូវការគាំទ្រចាំបាច់របស់កុមារពិការ។

## ៥.ការរៀបចំបរិស្ថានសាលារៀន

តាមរយៈការគាំទ្រពីអង្គការដៃគូអភិវឌ្ឍ ឬការប្រើប្រាស់ថវិកាតាមកម្មវិធី (PB) របស់សាលារៀន ដើម្បីសាងសង់ជម្រាលសម្រាប់សិស្សប្រើរទេះរុញ និងសម្រាប់ បង្គលក្ខណៈងាយស្រួលក្នុងថ្នាក់រៀន បង្គន់ ស្ទូនកុមារ។សាងសង់បង្កាន់ដៃនៅក្នុងបង្គន់ក៏មានសារៈប្រយោជន៍ផងដែរសម្រាប់សិស្សដែលមានការលំបាកក្នុងការបំលាស់ទី។

## ៦.ឧទាហរណ៍នៃការអនុវត្ត និងអនុសាសន៍



## ឧទាហរណ៍នៃការអនុវត្ត

ក្រុមការងារខេត្តកំពតបានសហការជាមួយសមាគមន៍ជនពិការភ្នែកកម្ពុជា ដើម្បីរៀបចំផែនទីខ្នងផ្ទះ ដោយកំណត់អត្តសញ្ញាណកុមារមានបញ្ហាមើលនៅក្នុងសាលារៀន ដូចខាងក្រោមនេះ៖

- ជួបប្រជុំជាមួយអាជ្ញាធរឱ្យដឹងពីចំនួនខ្នងផ្ទះ និងចំនួនគ្រួសារ ដោយសុំផែនទីរបស់ឃុំដើម្បីកំណត់ទីតាំងភូមិ។
- ដាក់បញ្ចូលអាជ្ញាធរមូលដ្ឋានដូចជា៖ ប្រធានភូមិ មេក្រុម នាយកសាលា គ្រូ និងសិស្ស ក្នុងដំណើរការរៀបចំផែនទីខ្នងផ្ទះ។
- កំណត់ពេលវេលាដើម្បីរៀបចំធ្វើផែនទីខ្នងផ្ទះ និងផែនការ សម្រាប់ក្រុមចុះទៅតាមភូមិដែលបានកំណត់នៅថ្ងៃណាមួយ។
- សម្រេចថាសមាជិកក្រុមនឹងចុះទៅកាន់ភូមិផ្សេងៗគ្នាក្នុងមូលដ្ឋាន។
- ក្រោយពេលចុះធ្វើផែនទីខ្នងផ្ទះ សមាជិកទាំងអស់ត្រូវចូលរួមប្រជុំដើម្បីធ្វើព្រាងផែនទីពិតរួមមួយដោយបង្ហាញពីទីតាំងផ្ទះដោយរាប់បញ្ចូលទាំងកុមារមានបញ្ហាមើល ហើយប្រើលេខកូដ និងពណ៌សម្រាប់ចំណាំ។
- ធ្វើបច្ចុប្បន្នភាពលើផែនទីខ្នងផ្ទះ និងរៀបចំផែនការតាមដានកុមារពិការដែលបានកំណត់អត្តសញ្ញាណ។





# ឧទាហរណ៍នៃការអនុវត្ត

## លទ្ធផលនៃផែនទីខ្លួនផ្ទះ

ពេលធ្វើផែនទីខ្នងផ្ទះនៅស្រុកសំរោង ខេត្តតាកែវ សមាជិកក្រុមការងារដឹងពីចំនួនកុមារពិការភាគច្រើនមានកម្រិតពិការធ្ងន់ធ្ងរ និង មួយចំនួនធំទៀតមានពិការភាពចម្រុះ។ ឧទាហរណ៍ កុមារមានបញ្ហាប្រព័ន្ធបញ្ហាចលនាខួរក្បាល(CP) និយាយ និងការលូតលាស់ខាងបញ្ញា។

គ្មានកុមារណាត្រូវបានកំណត់អត្តសញ្ញាណក្នុងសាលារៀននោះទេ។ ក្នុងករណីខ្លះឪពុកម្តាយបាននាំកូនទៅកន្លែងព្យាបាលឯកជន ឬមណ្ឌលស្តារលទ្ធភាពពលកម្មដើម្បីព្យាបាលចលនា ប៉ុន្តែត្រូវបានឈប់បន្ទាប់ពីទទួលសេវាបាន១ឆ្នាំ ឬពេលដែលពុំឃើញមានការរីកចម្រើន។ ឪពុកម្តាយទាំងអស់ចង់ឱ្យកូនទទួលសេវាព្យាបាលណាស់ ដើម្បីឱ្យពួកគេទៅសាលារៀនបាន ប៉ុន្តែមិនដឹងទៅរកសេវានៅកន្លែងណា។



## អនុសាសន៍

**សមាជិកក្រុមការងារគួរចំណាយពេលជាមួយក្រុមគ្រួសារកុមារពិការដូចជា៖**

-ពន្យល់ពីសារៈសំខាន់របស់កុមារពិការដែលទទួលបានការអប់រំទាន់ពេល។

-ដឹងពីតម្រូវការរបស់ក្រុមគ្រួសារ និងពិភាក្សាពីដំណោះស្រាយ (ឧទាហរណ៍ក្រុមគ្រួសារមិនអាចចំណាយលើថ្លៃធ្វើដំណើរទៅកាន់ឃ្លីនីកព្យាបាល)។

-ពិភាក្សាពីការគាំទ្រលើការអប់រំ និងវេជ្ជសាស្ត្រដែល ធ្វើឱ្យក្រុមគ្រួសារអាចបញ្ជូនកូនរបស់គាត់បាន។

-ក្រុមគ្រួសារដឹងថាសមាជិកក្រុមការងារនឹងពិនិត្យតាមដានលើមូលដ្ឋាននិយ័តភាពជាមួយក្រុមគ្រួសារ និងកុមារដើម្បីធានាថាពុំមានការរើសអើង។



# ជំហានទី៦ :ការរៀបចំផែនទីសិក្សា



**អ្នកទទួលខុសត្រូវ**

ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក ខណ្ឌ សាលារៀន

**អ្នកចូលរួមអនុវត្ត**

សហគមន៍ អាជ្ញាធរដែនដី និង ដៃគូអភិវឌ្ឍន៍

**សមាសភាគនៃជំហានទី៦**

១.ពិនិត្យស្ថិតិកុមារពិការ នៅក្នុងទិន្នន័យប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ឬតាមរយៈការចុះឈ្មោះចូលរៀន ដើម្បីស្វែងរកចំនួនកុមារពិការដែលមាននៅក្នុងសាលារៀនកាលពីឆ្នាំមុន ដែលអាចជួយយើងបានក្នុងការធ្វើផែនការសម្រាប់ធនធានមនុស្ស និងការគាំទ្រចាំបាច់លើការរៀបចំផែនទីខ្នងផ្ទះ ដើម្បីអនុវត្តក្នុងឆ្នាំសាកល្បង។

២.ជ្រើសរើសថ្ងៃសមរម្យណាមួយជាមួយនាយកសាលា និងគ្រូបង្រៀន ដើម្បីរៀបចំផែនទីសិក្សា ដោយពឹងផ្អែកលើចំនួនសិស្សក្នុងសាលារៀន និងផែនទីខ្នងផ្ទះ។ ការកំណត់ អត្តសញ្ញាណសិស្សដោយប្រើឯកសារជំនួយស្មារតី (កម្រងសំណួរ ចំណាយពេលពី១៥ទៅ២០នាទី)។ ប្រសើរបំផុតគឺការធ្វើការជាក្រុមដែលមានសមាជិកចំនួន០២នាក់យ៉ាងតិច ដែលអាចចូលរួមកំណត់អត្តសញ្ញាណកុមារពិការ ហើយពួកគាត់នឹងកំណត់ចំនួនថ្ងៃចាំបាច់សម្រាប់ការចុះធ្វើផែនទីសិក្សា។

៣.ធានាថាសមាជិកនៃក្រុមការងារទាំងអស់បានទទួលការ**បំប៉នស្តីពី** ការប្រើប្រាស់ឯកសារជំនួយស្មារតីដើម្បីកំណត់អត្តសញ្ញាណកុមារពិការ។

៤.រៀបចំការប្រជុំបន្ទាប់ពីការចុះធ្វើផែនទីសិក្សា ដោយវិភាគទិន្នន័យដែលប្រមូលបានតាមរយៈឯកសារជំនួយស្មារតីសម្រាប់កំណត់អត្តសញ្ញាណ និងបញ្ជីការគាំទ្រ ។ នេះជាដំណើរការនៃការរៀបចំបញ្ជីសិស្សពិការដែលត្រូវការសេវាគាំទ្រ ។ (ការអនុញ្ញាតឱ្យគ្រូរបស់សិស្សពិការចូលរួមពិភាក្សាក្នុងការប្រជុំគឺមានសារៈប្រយោជន៍សម្រាប់ក្រុមការងារដើម្បីឱ្យដឹងពីអ្វីដែលជាតម្រូវការរបស់សិស្សពិការ និងគ្រូដែលអាចផ្តល់អនុសាសន៍គាំទ្រ)។

**តារាងបញ្ជីការគាំទ្រ**

| ឈ្មោះសិស្សពិការ | ការគាំទ្រចាំបាច់ | អ្នកទទួលខុសត្រូវ |
|---|---|---|
| | | |

**៥.បែងចែកការទទួលខុសត្រូវសម្រាប់ការកំណត់អត្តសញ្ញាណសិស្សពិការ ក្នុងចំណោមសមាជិកនៃក្រុមការងារក្នុងស្រុក**

បំពេញកូឡោនទី៣នៅក្នុងតារាងដែលបានផ្តល់ឱ្យត្រង់ចំណុច ច៤ បន្ទាប់ពីចុះបញ្ជីឈ្មោះសិស្ស និងការគាំទ្រដែលពួកគេត្រូវការ។ សមាជិកក្រុមការងារដែលទទួលបានឈ្មោះសិស្សពិការនឹងបន្តការពិនិត្យតាមដានហើយអាចសរសេរលើទម្រង់ប្រឹក្សាយោបល់។ (សូមមើលក្នុងឧបសម្ព័ន្ធ៦កៈទម្រង់ប្រឹក្សាគ្រូ)។

ប្រសិនបើសិស្សម្នាក់ ត្រូវការបញ្ជូនទៅរកសេវាថៃទាំភ្នែក ត្រូវផ្តល់ច្បាប់ចម្លងទំនេរនៃទម្រង់ប្រឹក្សាយោបល់សម្រាប់សេវាថៃទាំភ្នែកឱ្យគ្រូ ឬឪពុកម្តាយរបស់សិស្សមុនពេលពួកគេទៅរកសេវាថៃទាំភ្នែក (សូមមើលក្នុងឧបសម្ព័ន្ធ៦ខៈ ទម្រង់ប្រឹក្សាយោបល់ថៃទាំភ្នែក)។ សេវាថៃទាំភ្នែកនឹងសរសេរលើទម្រង់ប្រឹក្សាយោបល់ហើយប្រគល់ទម្រង់នេះត្រឡប់ទៅឱ្យសិស្ស ឬឪពុកម្តាយវិញ។ គ្រូបង្រៀនគួរសុំច្បាប់ចម្លងទម្រង់ប្រឹក្សាយោបល់ដែលកន្លែងសេវាថៃទាំភ្នែកបានបំពេញរួមទាំងព័ត៌មានពីឧបករណ៍ជំនួយក្នុងការមើល និងការរៀបចំថ្នាក់រៀនតាមតម្រូវការរបស់សិស្ស។

### ៦.ឧទាហរណ៍នៃការអនុវត្ត និងអនុសាសន៍



## ឧទាហរណ៍នៃការអនុវត្ត

### លទ្ធផលនៃផែនទីខ្លួនផ្ទះ

ក្រោយពីការរៀបចំផែនទីខ្នងផ្ទះចប់ក្នុងស្រុកសំរោង ខេត្តតាកែវសមាជិកក្រុមការងារបានរកឃើញការគាំទ្រសំខាន់ៗ ចំនួនបី ដែលអាចបំពេញតម្រូវការបានច្រើនក្រោយពីកំណត់អត្តសញ្ញាណសិស្សមានបញ្ហារៀនសូត្រ។ **ការគាំទ្រសំខាន់ៗទាំងនោះគឺៈ**

- **ការបំប៉នគ្រូ** : គ្រូទាំងអស់ទទួលបានអត្ថប្រយោជន៍ពីវគ្គបំប៉នមូលដ្ឋាន នៃការអប់រំបញ្ចូលគ្នាតាមរយៈកម្មវិធីបំប៉ន ដែលអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា ហើយគ្រូខ្លះអាចទទួលការបំប៉នបន្ថែមដើម្បីបង្រៀនសិស្សមានបញ្ហារៀនសូត្រ។ វគ្គបំប៉នទាំងនេះផ្តល់វិធីអនុវត្តការបង្រៀនដល់គ្រូក្នុ ងថ្នាក់រៀន។
- **ការរៀបចំសម្រាប់ថ្នាក់បំប៉ន** : នៅពេលនាយកសាលាផ្តល់ថវិកា PB គ្រូអាចបង្រៀនបំប៉នដោយឥតគិតថ្លៃ ដើម្បីឱ្យសិស្សមានបញ្ហារៀនសូត្រអាចទទួលផលប្រយោជន៍ពីការបង្រៀននេះ។

-**ការផ្តល់ការគាំទ្របន្ថែមសម្រាប់សិស្ស** : អាចផ្តើមដោយដាក់បញ្ចូលនូវកម្មវិធីអាហារពេលព្រឹកដើម្បីឱ្យសិស្សបានទទួលទាន។ ដូច្នេះពួកគេអាចចាប់ផ្តើមយកចិត្តទុកដាក់រៀនពេញមួយថ្ងៃ។ ផ្តល់កង់ឱ្យសិស្សពិការដែលនៅឆ្ងាយ ដើម្បីឱ្យពួកគេមកសាលារៀនទៀងទាត់ ហើយទាន់ពេលវេលា។ ផ្តល់ការគាំទ្រដល់សិស្សពីរ ឬបីនាក់ ដែលត្រូវការសេវាវេជ្ជសាស្ត្រនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យខេត្តសម្រាប់សេវាថៃទាំភ្នែក។



## ឧទាហរណ៍នៃការអនុវត្ត

សាលាបឋមសិក្សាព្រៃអារ ស្រុកសំរោងដែលមានលោកនាយកសាលា **អ៊ឹម ស៊ីថុន** បានប្រើថវិកា (PB) ក្នុងការសាងសង់ជម្រាលនៅសាលារៀន និងបង្គន់ក្នុងពេលយុទ្ធនាការចុះឈ្មោះចូលរៀន ការចុះធ្វើផែនទីខ្នងផ្ទះ។ ˝ខ្ញុំចង់ឃើញសាលារៀនមានបរិស្ថានស្អាត មានពណ៌បៃតង និងមានសុវត្ថិភាពសម្រាប់កុមារជាពិសេសកុមារពិការ។ ខ្ញុំចង់បង្ហាញថាសាលារៀនបានយកចិត្តទុកដាក់ដល់កុមារពិការ ដោយអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នាដែលបាននិងកំពុងគាំទ្រពីរាជរដ្ឋាភិបាល ពិសេសក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍនានា និងសប្បុរសជន ។˝



## អនុសាសន៍

១.ជាការសំខាន់ណាស់ក្នុងការតាមដានលើផែនទីខ្នងផ្ទះ បន្ទាប់ពីផែនទីខ្នងផ្ទះត្រូវបានធានាថាសិស្សទាំងអស់នៅក្នុងសាលារៀនទទួលបានការគាំទ្រតាមតម្រូវការចាំបាច់។

២.ដើម្បីឱ្យផែនទីខ្នងផ្ទះមានប្រសិទ្ធភាព នាយកសាលា និងគ្រូពាក់ព័ន្ធត្រូវរៀបចំផែនការ និងចុះពិនិត្យតាមដាន។

## ជំហានទី៧: ការបំប៉នការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ



### អ្នកទទួលខុសត្រូវ

នាយកដ្ឋានបឋមសិក្សា ឬ នាយកដ្ឋានអប់រំកុមារតូច ឬ នាយកដ្ឋានមធ្យមសិក្សា

### អ្នកចូលរួមអនុវត្ត

នាយកដ្ឋានពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍

### សមាសភាគនៃជំហានទី៧

**១.ការបំប៉ននាយកសាលា នាយិកាសាលា និងគ្រូឈរថ្នាក់ស្តីពីការអប់រំបញ្ចូលគ្នា**

ក្រសួងអប់រំ យុវជន និងកីឡាផ្តល់វគ្គបំប៉នរយៈពេល០៥ថ្ងៃ ស្តីពីការអប់រំបញ្ចូលគ្នាដល់ក្រុមការងារបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMT) និងប្រធានក្រុមបច្ចេកទេសមកពីសាលារៀនសាកល្បងដើម្បីឱ្យពួកគេបំប៉នបន្តដល់គ្រូបង្រៀន។ គ្រូឈរថ្នាក់ទាំងអស់នឹងទទួលបានវគ្គបំប៉ននៅពេលណាមួយបន្ទាប់ពីសាលារៀនរបស់ពួកគាត់ត្រូវបានជ្រើសរើសសាកល្បង។

**២.បំប៉នគ្រូឈរថ្នាក់អំពីវិធីសាស្ត្របង្រៀនកុមារមានតម្រូវការពិសេសតាមកម្រិតថ្នាក់ដែលបានកំណត់**

ក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់ការបំប៉នរយៈពេល ០២ ឬ០៣ថ្ងៃ លើមុខវិជ្ជាជំនាញអំពី៖

- វិធី បង្រៀនសិស្សមានបញ្ហាមើល
- វិធី បង្រៀនសិស្សមានបញ្ហាបញ្ញា
- វិធីបង្រៀនសិស្សមានបញ្ហាស្តាប់

ការបំប៉ននេះនឹងធ្វើឡើងក្រោយពីបានកំណត់អត្តសញ្ញាណកុមារពិការ ។ ក្រុមការងារនឹងដឹងពីចំនួនសិស្សពិការដែលត្រូវការសេវាគាំទ្រ។ ផ្អែកលើចំនួនរបស់សិស្សដែលមានបញ្ហារៀនសូត្រ ក្រុមការងារអាចជ្រើសរើសគ្រូដែលត្រូវបំប៉នពីវិធីបង្រៀនសិស្សមានបញ្ហារៀនសូត្រក្នុងថ្នាក់អប់រំបញ្ចូលគ្នា។ ក្រុមការងារអាចជ្រើសរើសគ្រូដែលគួរតែទទួលបានការបំប៉នពីវិធីបង្រៀនសិស្សពិបាកក្នុងការមើលនៅថ្នាក់អប់រំ បញ្ចូលគ្នា។

ការបំប៉នពីវិធីបង្រៀនសិស្សពិបាកក្នុងការមើល អាចពន្យល់បន្ថែមអំពីបែបបទណែនាំ ស្តីពីសេវាថែទាំភ្នែកដល់គ្រូដើម្បីឱ្យពួកគាត់អាចយល់ពីអ្វីជាឧបករណ៍អុបទិក និងមិនមែន ជាឧបករណ៍អុបទិក ឬការផ្លាស់ប្តូរនៅក្នុងថ្នាក់រៀនស្របតាមតម្រូវការរបស់សិស្ស។ នៅពេលបែបបទណែនាំ ត្រូវបានបំពេញដោយអ្នកផ្តល់សេវាកម្មថែទាំភ្នែក ហើយផ្ញើត្រឡប់ទៅឱ្យសិស្ស គ្រូនឹងយល់ពីរបៀបនៃការពន្យល់ព័ត៌មានដែលមាននៅលើបែបបទណែនាំ។ គ្រូនឹងដឹងច្បាស់ថាសិស្សអាចប្រើឧបករណ៍អុបទិក ឬ ឧបករណ៍ មិនមែនអុបទិកតាមវេជ្ជបញ្ជា និងអាចផ្តល់ឱ្យសិស្សពិការនូវការគាំទ្រសមស្របក្នុងថ្នាក់រៀន។

## ៣.ឧទាហរណ៍នៃការអនុវត្ត និងអនុសាសន៍

# ឧទាហរណ៍នៃការអនុវត្ត

នៅសាលាបឋមសិក្សាកំពតក្រុង ក្នុងខេត្តកំពត ជាសាលារៀនសាកល្បងដែលទទួលបានការគាំទ្រពីអង្គការគ្រួសារថ្មី ហើយគ្រូទាំងអស់ទទួលបានការបំប៉នរយៈពេល ០៥ថ្ងៃពីការអប់រំបញ្ចូលគ្នា។ បន្ទាប់ពីសកម្មភាពអប់រំផ្សព្វផ្សាយតាមសហគមន៍ និងការចុះធ្វើផែនទីខ្នងផ្ទះបានរកឃើញសិស្សពិបាកក្នុងការមើលចំនួន៧នាក់។ គ្រូចំនួន៧នាក់ មកពីសាលារៀនសាកល្បងដែលត្រូវបង្រៀនសិស្សទាំងនោះទទួលបានវគ្គបំប៉នរយៈពេល០២ថ្ងៃអំពីការបង្រៀនសិស្សពិបាកក្នុងការមើលនៅក្នុងថ្នាក់អប់រំបញ្ចូលគ្នា។ អ្នកគ្រូ **គង់ ម៉ា រ៉ា** ជាគ្រូបង្រៀនសិស្សថ្នាក់ទី៥ បាននិយាយថា "ការរៀនអំពីព័ត៌មានដែលមាននៅក្នុងបែបបទណែនាំ ជាពិសេសទាក់ទងនឹងការប្រើប្រាស់ឧបករណ៍អុបទិ ឧបករណ៍មិនមែនអុបទិកក និង ការផ្លាស់ប្តូរស្ថានភាពនៅថ្នាក់រៀន វគ្គបំប៉ននេះគឺមានប្រយោជន៍ណាស់។ នៅពេលខ្ញុំទទួលបានបែបបទណែនាំពីសេវាថែទាំភ្នែក ខ្ញុំអាចយល់ពីអ្វីដែលជាការគាំទ្រ ហើយត្រូវផ្តល់ឱ្យសិស្ស និងជួយសិស្សថ្មីរបស់ខ្ញុំ។ អង្គការគ្រួសារថ្មីបានផ្តល់ជើងទម្រ កែវពង្រីកមានដៃតាមវេជ្ជបញ្ជា។ សិស្ស **ឆេង កញ្ញារត្តី** ជាសិស្សពិបាកក្នុងការមើលរៀនថ្នាក់ទី៥ បានប្រើប្រាស់ជើងទម្រ និងកែវពង្រីកគ្រប់ពេល ។ ខ្ញុំរៀបចំនាងឱ្យអង្គុយជួរទី២នៅខាងមុខដើម្បីឱ្យនាងអាចអានអក្សរនៅលើក្តារខៀនបានយ៉ាងងាយស្រួល និងឱ្យមិត្តរួមថ្នាក់ ២នាក់អង្គុយអមសងខាងដើម្បីជួយនៅពេលនាងមិនសូវយល់។"



## អនុសាសន៍

១.នាយកសាលា នាយិកាសាលា និងគ្រូទាំងអស់ត្រូវតែយល់អំពីពិការភាព តម្រូវការរបស់កុមារពិការ និងវិធីជួយកុមារពិការនៅ ក្នុងថ្នាក់រៀន និងសាលារៀនអប់រំបញ្ចូលគ្នាប្រកបដោយប្រសិទ្ធភាពខ្ពស់។

២.បន្ទាប់ពីការធ្វើផែនទីខ្នងផ្ទះ ការផ្តល់វគ្គបំប៉នពីវិធីបង្រៀនពិសេសដល់គ្រូដែលត្រូវបានជ្រើសរើស ដើម្បីជួយពួកគាត់ឱ្យមានចំណេះដឹងពីវិធីជួយសិស្សដែលមានបញ្ហាមើល ឬបញ្ហារៀនសូត្រក្នុងថ្នាក់រៀនអប់រំបញ្ចូលគ្នា។

# ជំហានទី៨ : ការតាមដានលើការបញ្ជូនកុមារពិការទៅកន្លែងផ្តល់សេវា



**អ្នកទទួលខុសត្រូវ**

នាយកដ្ឋានបឋមសិក្សា ឬ នាយកដ្ឋានអប់រំកុមារតូច ឬ នាយកដ្ឋានមធ្យមសិក្សា

**អ្នកចូលរួមអនុវត្ត**

នាយកដ្ឋានពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍន៍

**សមាសភាគនៃជំហានទី៨**

**១.ការផ្តល់ការគាំទ្រសមស្រប**

ប្រើប្រាស់តារាងបញ្ជីឈ្មោះកុមារពិការដែលបានកំណត់អត្តសញ្ញាណ និងតារាងកំណត់តម្រូវការចាំបាច់ដែលបង្ហាញក្នុងចំណុច៤(ជំហានទី៦) ដើម្បីតាមដានសិស្សពិការ និងក្រុមគ្រួសាររបស់គេ។ សៀវភៅរាយឈ្មោះសេវាកម្មមានសារៈប្រយោជន៍ផងដែរ ដែលអាចឱ្យយើងដឹងពីទីកន្លែងត្រូវបញ្ជូនសិស្ស និងក្រុមគ្រួសារ។ ថវិកាគាំទ្រដោយអង្គការសម្រាប់ថ្លៃធ្វើដំណើរចំពោះក្រុមគ្រួសារដែលទៅទទួលសេវាព្យាបាលគឺសំខាន់ណាស់ហើយ ក៏មានសារៈប្រយោជន៍ផងដែរ ចំពោះក្រុមគ្រួសារបើសិនជាសមាជិកក្រុមការងារអមដំណើរជាមួយពួកគេ។ ក្នុងករណីខ្លះក្រុមការងារអាចទំនាក់ទំនងជាមួយអង្គការដទៃទៀតនៅក្នុងតំបន់ ដែលផ្តល់សេវាគាំទ្រចាំបាច់។ឧទាហរណ៍អង្គការគ្រួសារថ្មីសហការជាមួយសមាគមន៍ជនពិការភ្នែកកម្ពុជា(ABC)ដើម្បីវាស់កម្រិតនៃបញ្ហាមើល និងសេវាកម្មសុខភាពភ្នែក(Fred Hollows Foundation) ដោយផ្តល់ការវាយតម្លៃកម្រិតបញ្ហាមើល។ សេវាកម្មភ្នែកត្រូវបំពេញបែបបទណែនាំពីសេវាថែទាំភ្នែក ហើយផ្តល់ច្បាប់ចម្លងឱ្យសិស្ស និងក្រុមគ្រួសារនាយកសាលា និងគ្រូបង្រៀន។

ក្នុងករណីផ្សេងទៀត អង្គការអាចរៀបចំដោយផ្តល់ការគាំទ្រចាំបាច់ដល់សិស្ស ។ ជាឧទាហរណ៍នៅស្រុកថ្មគោល អង្គការជនពិការអន្តរជាតិបារាំងបានចំណាយថវិកាទិញកង់ឱ្យសិស្សពិការ ដែលចូលរៀនដោយសារសាលារៀននៅឆ្ងាយពីផ្ទះរបស់គេ។ ស្រដៀងគ្នានេះដែរ នៅស្រុកសំរោង អង្គការកាតូលិកសង្គ្រោះ និង អភិវឌ្ឍន៍បានរៀបចំការវាយតម្លៃបន្ថែមដល់សិស្សដែលត្រូវបញ្ជូនដោយគ្រូ និងរៀបចំឱ្យសិស្សភាគច្រើនចូលរៀនក្នុងថ្នាក់ដែលបានបំប៉នពីការអប់រំបញ្ចូលគ្នា។

នៅថ្នាក់រៀន គ្រូអាចជួយគាំទ្រដូចជាការផ្លាស់ប្តូរទីតាំងអង្គុយរបស់សិស្ស។ ប្រសិនបើជាសិស្សត្រូវការជំនួយបន្ថែមទៀត គឺត្រូវឱ្យអង្គុយជិតសិស្សពូកែដែលអាចជួយពួកគេបាន។ គ្រូបង្រៀនដែលទទួលវគ្គបំប៉នពីការអប់រំបញ្ចូលគ្នា និងវគ្គជំនាញសម្រាប់បង្រៀនសិស្សមានបញ្ហាមើល ឬជាមួយសិស្សមានបញ្ហារៀនសូត្រនឹងមានចំណេះដឹងពីវិធីអនុវត្តក្នុងថ្នាក់រៀន។

**២. ការប្រើប្រាស់បែបបទណែនាំ និង ការពិនិត្យតាមដានភាពរីកចម្រើនរបស់សិស្ស**

ឧទាហរណ៍៖ ការប្រើប្រាស់បែបបទណែនាំពីសេវាថែទាំភ្នែក ដើម្បីរក្សាឯកសារផ្តល់ការគាំទ្រ និងពិនិត្យតាមដានភាពរីកចម្រើនរបស់សិស្សពិបាកមើល បែបបទណែនាំពីសេវាថែទាំភ្នែកជាវិធីងាយស្រួលមួយសម្រាប់ស្ថាប័នពាក់ព័ន្ធទាំងអស់ដោយរាប់បញ្ចូលទាំងគ្រូនាយកសាលា ក្រុមគ្រួសារ ក្រុមការងារ និងក្រុម

ពិនិត្យតាមដាន ដើម្បីតាមដាននិងធ្វើឱ្យប្រាកដថាសិស្សពិការម្នាក់ៗទទួលបានការគាំទ្រសមស្រប និងភាពរីកចម្រើនរបស់សិស្សពិការ។ (សូមមើល**ឧបសម្ព័ន្ធ**៦កៈ បែបបទណែនាំពីសេវាថែទាំភ្នែក)

**៣.ឧទាហរណ៍នៃការអនុវត្ត និងអនុសាសន៍**



## ឧទាហរណ៍នៃការអនុវត្ត

### គ្រូជំនួយចល័ត

ក្រុមការងារស្រុកថ្មគោល ខេត្តបាត់ដំបង តាមរយៈអង្គការជនពិការអន្តរជាតិ បានគាំទ្រគ្រូបង្រៀនចំនួន ០៤ នាក់នៅក្នុងសាលារៀនសាកល្បង ដើម្បីក្លាយជាគ្រូជំនួយចល័ត។ គ្រូជំនួយចល័តទាំងនោះបានទទួលការបណ្តុះបណ្តាលបន្ថែម ដើម្បីផ្តល់សេវាពិនិត្យតាមដានកុមារពិការពីរករណីៈ

១.សេវាតាមផ្ទះរួមមានៈ ការបង្រៀន និងប្រឹក្សាដល់ឪពុកម្តាយឱ្យដឹងពីរបៀបថែទាំកូនរបស់ពួកគាត់

២. នៅសាលារៀនដោយមានការជួយដល់គ្រូបន្ទុកថ្នាក់ក្នុងការផលិតសម្ភារៈឧបទេសនិង ផ្តល់ជំនួយបច្ចេកទេសលើវិធីបង្រៀននៅពេលចាំបាច់។

### ការដឹកនាំសាលារៀន

លោក **សុខារ័ត្ន** ជានាយកសាលាបឋមសិក្សាកំពតក្រុង ខេត្តកំពត។ សាលារៀនរបស់គាត់បាន ទទួលការគាំទ្រដោយអង្គការគ្រួសារថ្មីលើការអប់រំបញ្ចូលគ្នាសម្រាប់សិស្សខ្សោយក្នុងការមើល។ ក្នុងឆ្នាំ២០១១ បានកំណត់រកឃើញសិស្សខ្សោយក្នុងការមើលចំនួន០៧នាក់។ លោកប្តេជ្ញាចិត្ត ថានឹងធានាឱ្យមានការរីកចម្រើនក្នុងការរៀនសូត្រ ចំពោះសិស្សពិការទាំងនោះ។ គាត់ស្គាល់ឈ្មោះពួកគេ ហើយពិនិត្យតាមដានពួកគេនៅក្នុងថ្នាក់រៀនជាទៀងទាត់ដោយមានការប្រជុំជាមួយគ្រូទាំងអស់។ គាត់ស្គាល់កន្លែងរស់នៅរបស់សិស្សពិការ ហើយអាចចង្អុលប្រាប់ពីផ្ទះរបស់គេនៅលើផែនទីខ្នងផ្ទះទៀតផង។





# អនុសាសន៍

១.សាលារៀននីមួយៗគួរបង្កើតហឹបរៃអង្គាសថវិកាសម្រាប់ជួយគាំទ្រដល់កុមារពិការ និងក្រុមគ្រួសារកុមារពិការដែលបញ្ជូនទៅទទួលសេវា។

២.សាលារៀននីមួយៗគួរសហការល្អ និងធ្វើការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដាក់បញ្ចូលការគាំទ្រកុមារពិការក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ដើម្បីទទួលបានថវិកាគាំទ្រពីឃុំ សង្កាត់។

៣.អង្គការដៃគូគួរតែគាំទ្រថវិកា សម្រាប់ថ្លៃធ្វើដំណើរដល់ក្រុមគ្រួសារ ដែលទៅទទួលសេវាបញ្ជូន និងការគាំទ្រដល់សិស្សពិការបន្ថែមទៀតដែលត្រូវការចាំបាច់ដូចជាកង់ជាដើម។ ក្រុមគ្រួសារអាចទទួលសេវាគាំទ្រសុខភាពដោយឥតគិតថ្លៃ ឬបញ្ចុះតម្លៃទាបដោយប្រើប័ណ្ណក្រីក្រនៅកន្លែងណាដែលមានលទ្ធភាព។

៤.វាមានសារៈប្រយោជន៍ចំពោះក្រុមគ្រួសារ បើសិនជាសមាជិកក្រុមការងារអមដំណើរបញ្ជូនទៅរកសេវាជាមួយ។

៥.ការសហការល្អជាមួយអង្គការដៃគូផ្សេងទៀតក្នុងមូលដ្ឋាន ដែលផ្តល់សេវាគាំទ្រជាក់លាក់ ហើយត្រូវប្រាកដថាសិស្សអាចទទួលការគាំទ្រទាំងអស់ដែលចាំបាច់។

៦.ទម្រង់ប្រឹក្សាគ្រូគួរប្រើប្រាស់ ដើម្បីរក្សាទុកឯកសារដែលអាចប្រើប្រាស់បាន ចំពោះស្ថាប័នពាក់ព័ន្ធដោយពណ៌នាពីតម្រូវការរបស់សិស្សពិការ ។



# ជំហានទី៩ :ការពិនិត្យតាមដានការរីកចម្រើនរបស់កុមារពិការ



**អ្នកទទួលខុសត្រូវ**

ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក ខណ្ឌ ( DTMT )

**អ្នកចូលរួមអនុវត្ត**

សាលារៀន និង ដៃគូអភិវឌ្ឍន៍

**សមាសភាគនៃជំហានទី៩**

**១.ការបង្កើតផែនការពិនិត្យតាមដាន**

- សមាជិកក្រុមការងារ រួមទាំងក្រុមការងារបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMT) នឹងត្រូវពិនិត្យតាមដានរៀងរាល់ត្រីមាស ។
- គ្រូបង្រៀនពិនិត្យតាមដានពីការរីកចម្រើនរបស់សិស្សជាប្រចាំហើយរាយការណ៍ជូននាយកសាលា នាយិកាសាលា។

-ក្រុមការងារថ្នាក់ជា តិនឹងពិនិត្យតាមដានលទ្ធផលការងារប្រចាំឆមាសនៅតាមសាលាគោលដៅ។

**២.ការប្រើប្រាស់ទម្រង់ស្របតាមកម្រិតនីមួយៗ**

លោកគ្រូ អ្នកគ្រូត្រូវធ្វើការពិនិត្យតាមដានដោយប្រើទម្រង់វាយតម្លៃសកម្មភាពសិក្សា និងឥរិយាបថរបស់សិស្សពិការ។ ព័ត៌មានទាក់ទងទៅនឹងការរីកចម្រើនរបស់សិស្ស បញ្ហាឧបសគ្គនានា ព្រមទាំងដំណោះស្រាយងាយៗ ដែលបានធ្វើ ត្រូវរាយការណ៍ជូននាយកសាលា នាយិកាសាលា។

សមាជិកក្រុមការងារនឹងប្រើប្រាស់នូវទម្រង់ពិនិត្យតាមដាន ស្ថិតិសិស្សនៅតាមសាលារៀនដែលបានភ្ជាប់ជូន (ឧបសម្ព័ន្ធ៩ក) ដោយដកស្រង់នូវទិន្នន័យ ព័ត៌មានចេញពីបញ្ជីចុះឈ្មោះរបស់សាលា និងទម្រង់វាយតម្លៃសកម្មភាពសិក្សា និងឥរិយាបថរបស់សិស្សពិការ។

ក្រុមការងារនៃនាយកដ្ឋានបឋមសិក្សានឹងពិនិត្យទម្រង់ស្ថិតិសាលារៀនដែលបានភ្ជាប់ជូនៈ

- ទម្រង់ស្ថិតិសាលារៀននៅកម្រិតក្រុង ស្រុក ខណ្ឌ (ឧបសម្ព័ន្ធ៩ខ)
- ទម្រង់សង្កេតសាលារៀន (ឧបសម្ព័ន្ធ៩គ)
- ទម្រង់សង្កេតថ្នាក់រៀន( ឧបសម្ព័ន្ធ៩ឃ)

ទម្រង់ទាំងនេះប្រើប្រាស់នូវបទដ្ឋានអន្តរជាតិ សម្រាប់គុណភាពនៃការអប់រំបញ្ចូលគ្នា និងជំហានសម្រាប់ការអនុវត្តដំណើរការនៃប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ ដែលបានបរិយាយនៅក្នុងសៀវភៅណែនាំ ដើម្បីវាស់វែងការអនុវត្តប្រកបដោយជោគជ័យ និងមានគុណភាព។

៣.ឧទាហរណ៍នៃការអនុវត្ត និងអនុសាសន៍



## ឧទាហរណ៍នៃការអនុវត្ត

រៀងរាល់ពីរខែម្តង ក្រុមការងារពិនិត្យតាមដានមកពីអង្គការគាំទ្រ ដូចជា៖ អង្គការគ្រូសារថ្មី បានចុះពិនិត្យតាមដាននៅសាលារៀនសាកល្បងកំពតក្រុង។ ដោយជួបជាមួយគ្រូបង្រៀន និងនាយក សាលាដើម្បីសង្កេតមើលការរីកចម្រើនរបស់សិស្សមានបញ្ហាមើលទាំងអស់ និងបញ្ហាដែលសិស្ស គ្រូ បង្រៀន និងនាយកសាលាកំពុងជួបប្រទះ។ ការចុះពិនិត្យតាមដានបានធ្វើនៅខែធ្នូ ឆ្នាំ២០១១ ក្រុមពិនិត្យតាមដានបានដឹងថាសិស្សមានបញ្ហាមើលមានមិត្តភក្តិជាច្រើន។

គ្រូបានប្រើបែបបទណែនាំពីសេវាថែទាំភ្នែករបស់គ្រូ ដើម្បីឱ្យដឹងពីតម្រូវការរបស់សិស្សពិការហើយពិនិត្យតាមដានលើអនុសាសន៍ ដែលមានក្នុងបែបបទណែនាំដោយឱ្យសិស្សអង្គុយតុមុខជិត បង្អួច ឬជាមួយសិស្សដែលមិនមានបញ្ហាមើល។ សិស្សបានប្រើប្រាស់ជើងទម្រ ឬឧបករណ៍សរសេរ សម្រាប់សិស្សពិការភ្នែក (slates) ដែលមានពណ៌។ គ្រូបានបង្កើតសម្ភារៈបង្រៀនជាមួយនឹងអក្សរពុម្ព ធំសម្រាប់សិស្សពិការ។



## អនុសាសន៍

១.ក្រុមពិនិត្យតាមដានទាំង៣កម្រិត (ខេត្ត ស្រុក សាលារៀន) ត្រូវ អនុវត្តផែនការពិនិត្យតាមដានដែលបានចងក្រង ដើម្បីឱ្យប្រាកដថាការអប់រំបញ្ចូលគ្នាត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

២.ក្រុមពិនិត្យតាមដាន ត្រូវបន្តផ្តល់អនុសាសន៍ដល់គ្រូបង្រៀនជាបន្តបន្ទាប់ ដើម្បីឱ្យពួកគាត់បន្តប្រើប្រាស់ទម្រង់ប្រឹក្សារបស់គ្រូសម្រាប់សិស្សម្នាក់ៗ ក្នុងការពិនិត្យតាមដានការរីកចម្រើនរបស់សិស្ស។

៣.គ្រូបង្រៀនគួរតែប្រើប្រាស់ទម្រង់ប្រឹក្សារបស់គ្រូ ដើម្បីពិនិត្យតាមដានភាពរីកចម្រើនរបស់សិស្សហើយកំណត់នូវការគាំទ្រ និងតម្រូវការរបស់សិស្សបន្ថែមទៀត ប្រសិនបើសិស្សមិនមានការរីកចម្រើនទៅតាមការកំណត់ ។

៤.ក្រុមពិនិត្យតាមដានប្រើប្រាស់ឧបករណ៍ ពិនិត្យតាមដាន និងពីរបៀបផ្តល់អនុសាសន៍ និង ព័ត៌មានត្រឡប់ល្អៗ។

# ការសង្កេតសាលារៀន

## ( នាយក / នាយិកាសាលា )

## I. ព័ត៌មានទូទៅ

១- ឈ្មោះសាលា ……………………………… លេខទូរស័ព្ទ៖........................................

២-ភូមិ................ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ.................ខេត្ត/រាជធានី.................

៣- ឈ្មោះនាយក / នាយិកា………………………………….……..ភេទ…....…..

៤- បទពិសោធន៍នៃការគ្រប់គ្រង……………..……..

៥- ចំនួនគ្រូសរុប ………….........នាក់ ស្រី…....….. នាក់

៦- ចំនួនសិស្សសរុប….................…នាក់ ស្រី……....… នាក់

៧- ចំនួនសិស្សពិការសរុប…...……....នាក់ ស្រី…....……នាក់

៨- ប្រភេទពិការ

- បញ្ហាចលនា……………..នាក់
- បញ្ហាមើល……….....……..នាក់
- បញ្ហាស្តាប់………....…..នាក់
- បញ្ហានិយាយ…….......…..នាក់
- បញ្ហាបញ្ញា……………......នាក់
- បញ្ហាផ្សេងៗ....................នាក់

## II. ការសង្កេត

| ល.រ | សកម្មភាព | មាន | មិនមាន | មតិរបស់អ្នកអង្កេត |
|---|---|---|---|---|
| ១ | មានផែនការអភិវឌ្ឍន៍សាលាប្រចាំឆ្នាំ | | | |
| ២ | បានរៀបចំផែនទីសិក្សាសម្រាប់កុមារពិការក្នុងសាលាដែលបានកំណត់រួច | | | |
| ៣ | បានរៀបចំក្រុមការងារមានអ្នកតំណាងគ្រប់កម្រិតទាំង៤ដូចក្នុងគោលការណ៍ណែនាំ | | | |
| ៤ | ក្រុមការងារបានទទួលវគ្គបំប៉នការអប់រំផ្សព្វផ្សាយពីពិការភាព សូចនាករនៃគុណភាពការអប់រំបញ្ចូលគ្នា ការរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយនៅសហគមន៍ ការប្រើប្រាស់តារាងកំណត់អត្តសញ្ញាណកុមារពិការ ការគ្រប់គ្រងការអប់រំបញ្ចូលគ្នាដល់នាយកសាលា នាយិកាសាលា ការអប់រំបញ្ចូលគ្នា និងសិទ្ធិទទួលបានការអប់រំរបស់កុមារ ) | | | |

| | | | | |
|---|---|---|---|---|
| ៥ | គ្រូពាក់ព័ន្ធទទួលបានវគ្គបំប៉នឯកទេស ការបង្រៀនសិស្សពិបាកក្នុងការមើល ពិបាកក្នុងការរៀនសូត្រ និងពិបាកក្នុងការស្តាប់) | | | |
| ៦ | រៀបចំសកម្មភាពអប់រំផ្សព្វផ្សាយដល់សហគមន៍ | | | |
| ៧ | សាលារៀនបានរៀបចំយុទ្ធនាការចុះឈ្មោះចូលរៀនដើម្បីប្រមូលកុមារទាំងអស់ឱ្យបានចូលរៀនរាប់បញ្ចូលទាំងកុមារពិការ | | | |
| ៨ | បានរៀបចំផែនទីខ្នងផ្ទះសម្រាប់កុមារពិការក្រៅសាលា | | | |
| ៩ | សាលាមានស្ថិតិសិស្សពិការច្បាស់លាស់ | | | |
| ១០ | សាលាបានដាក់របៀបវារៈ នៃការអប់រំបញ្ចូលគ្នា ក្នុងការប្រជុំប្រចាំខែ | | | |
| ១១ | បានកំណត់ការគាំទ្រសមស្របរបស់កុមារពិការដោយបានប្រើប្រាស់ទម្រង់នៃតារាងគាំទ្រចាំបាច់ | | | |
| ១២ | បានជូនព័ត៌មានស្តីពីសេវាបញ្ជូនសមស្របដល់ក្រុមគ្រួសារកុមារពិការក្នុងសាលា និងក្រៅសាលា | | | |
| ១៣ | ក្រុមការងារតាមដាន ក្រុមគ្រួសារពីការបញ្ជូនទៅរកសេវាវេជ្ជសាស្ត្រ | | | |
| ១៤ | បានកំណត់ តម្រូវការចាំបាច់របស់កុមារពិការ (ឧទាហរណ៍៖ ពី"ទម្រង់នៃតារាងតម្រូវការចាំបាច់" និងពីសេវាបញ្ជូន) | | | |
| ១៥ | បានរៀបចំទីធ្លាសាលាឱ្យមានបរិស្ថានសមស្រប/អនាម័យនិងមានភាពទាក់ទាញសម្រាប់កុមារពិការ | | | |
| ១៦ | សាលារៀនមានកម្មវិធី និងសកម្មភាពពិសេសដើម្បីលើកទឹកចិត្តកុមារពិការឱ្យចូលរៀន(ឧទាហរណ៍៖ ប្រអប់លើកទឹកចិត្ត ទិវាកុមារអន្តរជាតិ ទិវាជនពិការអន្តរជាតិ) | | | |
| ១៧ | សាលារៀនមានកម្មវិធីនិងសកម្មភាពពិសេស ដើម្បីលើកទឹកចិត្តកុមារពិការឱ្យចូលរៀន (ឧទាហរណ៍៖មេរៀនបំប៉នបន្ថែម អាហារពេលព្រឹក ឬអាហារថ្ងៃត្រង់ សកម្មភាពកុមារដើម្បីកុមារ ពិនិត្យតាមដានជាទៀងទាត់លើទម្រង់ប្រឹក្សាគ្រូ ) | | | |
| ១៨ | បង្កលក្ខណៈងាយស្រួលសម្រាប់រទេះរុញនៅសាលារៀន (ឧទាហរណ៍៖ ច្រកចេញចូល ការសាងសង់ជម្រាល សាលា | | | |

| | | | | |
|---|---|---|---|---|
| | រៀនយ៉ាងណាស់ត្រូវសាងសង់ជម្រាល ដើម្បីឱ្យកុមារពិការប្រើប្រាស់រទេះរុញ បង្គន់ មានបង្កាន់ដៃ សួនកុមារបង្កឱ្យមានលក្ខណៈងាយស្រួល និងប្រភពទឹក) | | | |
| ១៩ | សាលារៀនអនុវត្តការបង្ការនឹងពិការភាព (ឧទាហរណ៍៖ អប់រំកុមារឱ្យចេះលាងដៃជាមួយសាប៊ូបន្ទាប់ពីបន្ទោរបង់រួច ជៀសវាងការឆ្លងមេរោគដល់ត្រចៀកនិងភ្នែកដែលអាចបង្កឱ្យមានបញ្ហាក្នុងការស្តាប់ឬមើល) | | | |
| ២០ | សាលាបានជំរុញ និងលើទឹកចិត្ត គ្រូក្នុងការអនុកម្មវិធីអប់រំបញ្ចូលគ្នា | | | |
| ២១ | សាលាបានជំរុញគ្រូឱ្យរៀបចំថ្នាក់រៀនឱ្យមានការទាក់ទាញកុមារ និងធ្វើឱ្យកុមារចង់រៀន | | | |
| ២២ | សិស្សពិការក្នុងថ្នាក់រៀនស្របទៅនឹងអាយុ ឧទាហរណ៍ សិស្សអាយុ៨ឆ្នាំគឺត្រូវរៀនថ្នាក់ទី២ ឬថ្នាក់ទី៣ | | | |
| ២៣ | ក្រុមការងារបានចុះពិនិត្យតាមដានការអនុវត្តកម្មវិធីយ៉ាងហោចណាស់៣ដងក្នុងមួយឆ្នាំ) | | | |

## III. យោបល់នាយកសាលា

១. តើការគ្រប់គ្រង និងការអនុវត្តការអប់រំបញ្ចូលគ្នាជួបបញ្ហាប្រឈមអ្វីខ្លះ?

…………………………………………………………………………………………………

…………………………………………………………………………………………………

…………………………………………………………………………………………………

…………………………………………………………………………………………………

…………………………………………………………………………………………………

២. តើត្រូវការជំនួយបច្ចេកទេសអ្វីខ្លះបន្ថែមទៀតដើម្បីឱ្យការអនុវត្តការអប់រំបញ្ចូលគ្នាមាន ដំណើរការកាន់តែប្រសើរឡើង?

…………………………………………………………………………………………………

…………………………………………………………………………………………………

…………………………………………………………………………………………………

…………………………………………………………………………………………………

៣. តើសាលាមានផែនការធ្វើអ្វីខ្លះដើម្បីកែលំអការអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នាក្នុងខែខាងមុខនេះ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

អ្នកចុះសង្កេត

ហត្ថលេខា……………………………….

ឈ្មោះ……………………………………….

តួនាទី…………………………………………

កាលបរិច្ឆេទ………………………………..

អ្នកចុះសង្កេត

ហត្ថលេខា……………………………….

ឈ្មោះ……………………………………….

តួនាទី…………………………………………

កាលបរិច្ឆេទ………………………………..

យោបល់នាយក /នាយិកា

ឈ្មោះ៖............................

...........................................................................................................................

...........................................................................................................................

...........................................................................................................................

...........................................................................................................................

...........................................................................................................................

...........................................................................................................................

……………….ថ្ងៃទី………ខែ……………….ឆ្នាំ២០១……

ហត្ថលេខា

# ឧបសម្ព័ន្ធ ៩ក

## ទម្រង់ស្ថិតិសាលារៀន

## សម្រាប់ប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ

## បំពេញដោយក្រុមការងារ និងបុគ្គលិកសិក្សា

ខេត្ត..................ស្រុក.....................ឃុំ/សង្កាត់.......................កម្រងសាលារៀន.....................

សាលារៀន......................................កាលបរិច្ឆេទ..........................................

| | | ប្រភព | សរុប | ស្រី |
|---|---|---|---|---|
| ១ | ចំនួនសិស្សបច្ចុប្បន្នក្នុងសាលារៀន | បញ្ជីឈ្មោះសាលា | | |
| ២ | ចំនួនសិស្សពិការបច្ចុប្បន្នក្នុងសាលា | បញ្ជីឈ្មោះសិស្សពិការ | | |
| ៣ | ភាគរយកុមារពិការក្នុងចំណោមសិស្សសរុបនៃឆ្នាំសិក្សាថ្មី<br>[បច្ចុប្បន្ន : ភាគរយ ១]<br>គណនា ៖ $\frac{\text{ចំនួនកុមារពិការថ្មីក្នុងសាលា[សូចនាករលេខ២]}\times ១០០}{\text{ចំនួនសិស្សថ្មីក្នុងសាលា[សូចនាករលេខ១]}} =$ | | | |
| ៤ | ចំនួនកុមារពិការក្នុងឆ្នាំសិក្សាមុនការអនុវត្ត (Baseline) | បញ្ជីឈ្មោះសាលា | | |
| ៥ | ចំនួនសិស្សក្នុងឆ្នាំសិក្សាមុនការអនុវត្ត (Baseline) | បញ្ជីឈ្មោះសិស្ស | | |
| ៦ | ភាគរយកុមារពិការក្នុងសាលាមុនការអនុវត្ត<br>[Baseline: ភាគរយ 0]<br>គណនា ៖ $\frac{\text{ចំនួនកុមារពិការក្នុងសាលាមុនការអនុវត្តន៍}\times ១០០}{\text{ចំនួនសិស្សពិការក្នុងសាលាមុនការអនុវត្ត}} =$ | | | |
| ៧ | ភាគរយកើន ឬចុះរបស់កុមារពិការក្នុងសាលា<br>គណនា៖ $\frac{\text{ភាគរយ ១(ថ្មី)}-\text{ភាគរយ 0 }(Baseline)\times ១០០}{\text{ភាគរយ 0 }(Baseline)} =$ | | | |
| ៨ | ចំនួនកុមារពិការដែលត្រូវការការគាំទ្រចាំបាច់ | ទម្រង់កំណត់ | | |

| | | | | |
|---|---|---|---|---|
| | | អត្តសញ្ញាណលម្អិត | | |
| ៩ | ចំនួនកុមារពិការដែលទទួលការគាំទ្រចាំបាច់ | ទម្រង់ប្រឹក្សាគ្រូ | | |
| ១០ | ភាគរយកុមារពិការដែលទទួលការគាំទ្រចាំបាច់<br>គណនា៖ $\frac{\text{ចំនួនកុមារពិការដែលទទួលការគាំទ្រ[សូចនាករលេខ ៩] x ១០០}}{\text{ចំនួនកុមារពិការដែលត្រូវការការគាំទ្រចាំបាច់[សូចនាករលេខ ៨]}}=$ | | | |
| ១១ | ចំនួនកុមារពិការឡើងថ្នាក់<br>( គណនា៖ចំណាត់ថ្នាក់ទី១ - ចំណាត់ថ្នាក់ចុងក្រោយ ឬរយៈពេលនៃការសង្កេត ) | ប័ណ្ណរបាយការណ៍សិស្ស សៀវភៅកំណត់ត្រាគ្រូ | | |
| ១២ | ភាគរយកុមារពិការឡើងថ្នាក់<br>គណនា:$\frac{\text{ចំនួនកុមារពិការឡើងថ្នាក់[សូចនាករលេខ១១]×១០០}}{\text{ចំនួនកុមារពិការបច្ចុប្បន្នក្នុងសាលា [សូចនាករលេខ ២]}}=$ | | | |
| ១៣ | ចំនួនកុមារពិការបញ្ចប់ឆ្នាំសិក្សា និងឡើងថ្នាក់ថ្មី | សៀវភៅកំណត់ត្រាគ្រូ | | |
| ១៤ | ភាគរយកុមារពិការបញ្ចប់ឆ្នាំសិក្សា និងឡើងថ្នាក់ថ្មី<br>គណនា: $\frac{\text{ចំនួនកុមារពិការបញ្ចប់ឆ្នាំសិក្សា [សូចនាករលេខ ១៣] x ១០០}}{\text{ចំនួនកុមារពិការបច្ចុប្បន្នក្នុងសាលា [សូចនាករលេខ២]}}=$ | | | |

..................*ថ្ងៃទី*........*ខែ*..............*ឆ្នាំ*២០១...

*បានឃើញ និងឯកភាព* *អ្នកធ្វើតារាង*

# ឧបសម្ព័ន្ធ ឃ ការសង្កេតថ្នាក់រៀន

## I. ព័ត៌មានទូទៅ

ខេត្ត…………………………………ស្រុក/ខណ្ឌ…………………………………ឃុំ/សង្កាត់………………………………

កម្រងសាលារៀ………………………………………សាលារៀន……………………………………………………

ឈ្មោះគ្រូបង្រៀន…………………ភេទ…………កម្រិតវប្បធម៌…………………ក្របខ័ណ្ឌ………………………

អតីតភាពការងារ………………………………មុខវិជ្ជាបង្រៀន……………………………មេរៀ……………………

រយៈពេលបង្រៀន…………ថ្នាក់ទី………………………ចាប់ពីម៉ោង……………………ដល់……………………

សិស្សសរុប……………………នាក់ ស្រី……………………នាក់ សិស្សអវត្តមាន…………នាក់ ស្រី…………នាក់

ចំនួនសិស្សពិការ………………………នាក់ ស្រី………………នាក់ ប្រភេទពិការភាព……………………

កាលបរិច្ឆេទសង្កេត…………………………………………………………………………………………

## II. ការសង្កេត

| ល.រ | សកម្មភាព | មាន | មិនមាន | មតិរបស់អ្នកសង្កេត |
|---|---|---|---|---|
| ១ | មានកិច្ចតែងការបង្រៀនដែរឬទេ ? | | | |
| ២ | បានបញ្ចូលសកម្មភាពជួយសិស្សពិការក្នុងកិច្ចតែងការបង្រៀន | | | |
| ៣ | ប្រើប្រាស់សំភារៈឧបទេសសម្រាប់បង្រៀនសមស្រប | | | |
| ៤ | ជួយកុមារពិការនៅពេលជួបឬមានការលំបាកក្នុងការធ្វើកិច្ចការដែរ | | | |
| ៥ | លើកទឹកចិត្តកុមារពិការឲ្យបានចូលរួមគ្រប់សកម្មភាព | | | |
| ៦ | រៀបចំថ្នាក់រៀន ឬបរិស្ថានគួរឲ្យទាក់ទាញកុមារ និងធ្វើឲ្យកុមារចង់រៀនដែរ | | | |
| ៧ | បានធ្វើជាគំរូដល់សិស្សមិនពិការ (ឧទាហរណ៍ណែនាំដល់សិស្សមិន ឱ្យសើចចំអកឡកឡឺយមាក់ងាយឬករឿងដល់មិត្តរួមថ្នាក់) ដើម្បីកាត់បន្ថយការរើសអើងនៅក្នុងថ្នាក់ | | | |
| ៨ | ធ្វើការគាំទ្រជាទូទៅដល់សិស្សពិការនៅក្នុងថ្នាក់រៀន (ឧទាហរណ៍៖ រៀបចំសិស្សមិនពិការជាដៃគូជាមួយសិស្សពិការឱ្យចេះជួយគ្នា) | | | |
| ៩ | ធ្វើការគាំទ្រជាក់លាក់ដល់សិស្សពិការជាបុគ្គលនៅក្នុង | | | |

| | | | | |
|---|---|---|---|---|
| | ថ្នាក់រៀន (ឧទាហរណ៍៖ សិស្សមានបញ្ហាក្នុងការមើលឱ្យអង្គុយតុមុខ និងប្រើសម្ភារៈរូបី) | | | |
| ១០ | ថ្នាក់រៀនមានពន្លឺគ្រប់គ្រាន់ដើម្បីជួយដល់សិស្សពិបាកក្នុងការមើល | | | |
| ១១ | សិស្សទាំងអស់អាចផ្លាស់ទីយ៉ាងងាយស្រួលនៅក្នុងថ្នាក់រៀននិងអាចអានអក្សរលើក្តារខៀនបាន | | | |
| ១២ | គាំទ្រសិស្សដែលមានបញ្ហារៀនសូត្រ (ឧទាហរណ៍៖ ផ្តល់មេរៀនបំប៉នបន្ថែម ឱ្យសិស្សមាន ការផ្ចង់អារម្មណ៍លើមេរៀន...) | | | |
| ១៣ | រក្សាទុកទម្រង់ប្រឹក្សាគ្រូឬតារាងតាមដានភាពចម្រើនសិស្សពិការម្នាក់ៗជាទៀងទាត់ | | | |
| ១៤ | ទទួលវគ្គបំប៉នពីមូលដ្ឋាននៃការអប់រំបញ្ចូលគ្នាស្តីពីកុមារមានបញ្ហាមើល ស្តាប់ បញ្ញា | | | |
| ១៥ | ទទួលវគ្គបំប៉នពាក់ព័ន្ធនឹងឯកទេស | | | |
| ១៦ | តាមដានភាពរីកចម្រើនរបស់សិស្សពិការដោយភាពពេញចិត្តនិងមានផែនការផ្តល់ការគាំទ្របន្ថែមដល់សិស្ស ដែលពុំទាន់មានការរីកចម្រើនដោយពេញចិត្តដូចគ្នា | | | |

## III. យោបល់នាយកសាលា

១. ចំណុចល្អរបស់គ្រូ

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

២. ចំណុចខ្វះខាត

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

៣. ដំបូន្មានគរុកោសល្យ

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៤. យោបល់របស់គ្រូ និង អនុវត្តដំបូន្មានគរុកោសល្យ

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………

អ្នកចុះសង្កេត
ហត្ថលេខា………………………………
ឈ្មោះ……………………………………
តួនាទី…………………………………………
កាលបរិច្ឆេទ…………………………………

អ្នកចុះសង្កេត
ហត្ថលេខា………………………………
ឈ្មោះ……………………………………
តួនាទី…………………………………………
កាលបរិច្ឆេទ…………………………………

គ្រូប្រចាំថ្នាក់
ហត្ថលេខា………………………………
ឈ្មោះ……………………………………
កាលបរិច្ឆេទ…………………………………

គណគ្រប់គ្រងសាលា
ហត្ថលេខា………………………………
ឈ្មោះ……………………………………
តួនាទី…………………………………………
កាលបរិច្ឆេទ…………………………………

ទំព័រទី 10

**ក្រសួងអប់រំ យុវជន និងកីឡា**

**នាយកដ្ឋានបឋមសិក្សា**

**ឧបសម្ព័ន្ធ៩ខ-ឃ**

**ទម្រង់ពិនិត្យតាមដាន**

**ប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ**

*ឈ្មោះខេត្ត............................... កាលបរិច្ឆេទ............................... ចំនួនសាលារៀនអនុវត្តសរុប........................*

# ស្ថិតិស្រុក

*(ប្រភពទិន្នន័យ : ទម្រង់ស្ថិតិសាលារៀន ទម្រង់សង្កេតសាលារៀន ទម្រង់សង្កេតថ្នាក់រៀន )*

| | ឈ្មោះស្រុក | ឈ្មោះសាលា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ចំនួនសាលារៀនសរុបតាមស្រុកនីមួយៗ | សាលា............ | | សាលា.......... | | សាលា............ | | សាលា............ | |
| លរ | សូចនាករ | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ចំនួនសិស្សពិការបច្ចុប្បន្នគ្រប់សាលាសាកល្បងទាំងអស់តាមស្រុកនីមួយៗ | | | | | | | | |
| ២ | ចំនួនសិស្សពិការបច្ចុប្បន្នក្នុងសាលា | | | | | | | | |
| ៣ | ភាគរយកុមារពិការ [ភាគរយ ១: បច្ចុប្បន្ន]<br>គណនា ៖ $\frac{\text{ចំនួនសិស្សពិការថ្មីក្នុងសាលា[សូចនាករលេខ២]}\times ១០០}{\text{ចំនួនសិស្សថ្មីក្នុងសាលា[សូចនាករលេខ១]}} = \quad )$ | | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៤ | ចំនួនសិស្សទាំងអស់ក្នុងឆ្នាំសិក្សាមុនការអនុវត្តក្នុងសាលាគោលដៅ ( បឋម ) | | | | | | | | |
| ៥ | ចំនួនសិស្សពិការក្នុងឆ្នាំសិក្សាមុនការអនុវត្តក្នុងសាលាគោលដៅ ( បឋម ) | | | | | | | | |
| ៦ | ភាគរយកុមារពិការក្នុងសាលាមុនការអនុវត្តនៅសាលាគោលដៅ [ភាគរយ ០ : ( បឋម )<br>( គណនា ៖ ចំនួនសិស្សពិការក្នុងឆ្នាំសិក្សាដំបូង [សូចនាករលេខ ៥] x ១០០ / ចំនួនសិស្សក្នុងឆ្នាំសិក្សាដំបូង [សូចនាករលេខ ៤] = ) | | | | | | | | |
| ៧ | ភាគរយកើន ឬចុះរបស់សិស្សពិការគ្រប់សាលាគោលដៅ<br>( គណនា ៖ ភាគរយ ១ (ថ្មី)–ភាគរយ ០ (បឋម) x ១០០ / ភាគរយ ០ (បឋម) = ) | | | | | | | | |
| ៨ | ចំនួនសិស្សពិការដែលត្រូវការការគាំទ្រចាំបាច់គ្រប់សាលាសាកល្បងទាំងអស់ក្នុងស្រុកនីមួយៗ | | | | | | | | |
| ៩ | ចំនួនសិស្សពិការដែលទទួលការគាំទ្រចាំបាច់គ្រប់សាលាសាកល្បងទាំងអស់ក្នុង ស្រុកនីមួយៗ | | | | | | | | |
| ១០ | ភាគរយសិស្សពិការដែលទទួលការគាំទ្រចាំបាច់គ្រប់សាលាសាកល្បងទាំងអស់ក្នុងស្រុកនីមួយៗ<br>( គណនា ៖ ចំនួនកុមារពិការដែលទទួលការគាំទ្រ [សូចនាករលេខ ៩]×១០០ / ចំនួនកុមារពិការដែលត្រូវការការគាំទ្រចាំបាច់ [សូចនាករលេខ ៨] = ) | | | | | | | | |
| ១១ | ចំនួនសិស្សពិការឡើងថ្នាក់គ្រប់សាលាសាកល្បងទាំងអស់តាមស្រុកនីមួយៗ | | | | | | | | |
| ១២ | ភាគរយសិស្សពិការឡើងថ្នាក់គ្រប់សាលាសាកល្បងទាំងអស់តាមស្រុកនីមួយៗ<br>( គណនា ៖ ចំនួនកុមារពិការឡើងថ្នាក់ [សូចនាករលេខ ១១] ×១០០ / ចំនួនកុមារពិការបច្ចុប្បន្នក្នុងសាលា [សូចនាករលេខ ២] = ) | | | | | | | | |
| ១៣ | ចំនួនសិស្សពិការបញ្ចប់ឆ្នាំសិក្សា និងឡើងថ្នាក់ថ្មីគ្រប់សាលាសាកល្បង ទាំងអស់តាមស្រុកនីមួយៗ | | | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១៤ | ភាគរយសិស្សពិការបញ្ចប់ឆ្នាំសិក្សា និងឡើងថ្នាក់ថ្មីគ្រប់សាលាសាកល្បងទាំងអស់តាមស្រុកនីមួយៗ<br>( គណនា ៖ $\frac{\text{ចំនួនសិស្សពិការបញ្ចប់ឆ្នាំសិក្សា [សូចនាករលេខ ១៣] x ១០០}}{\text{ចំនួនសិស្សពិការបច្ចុប្បន្នក្នុងសាលា [សូចនាករលេខ២]}} =$ ) | | | | | | | | |
| ១៥ | ចំនួនសាលារៀនដែលមានពិន្ទុអប្បបរិមា ១៥/២០ ( អត្រា ៧៥% ) | | | | | | | | |
| ១៦ | ភាគរយសាលាដែលមានពិន្ទុអប្បបរិមា ១៥ ( អត្រា ៧៥% ) ក្នុងស្រុកនីមួយៗ<br>( គណនា ៖ $\frac{\text{ចំនួនសាលារៀនដែលមានពិន្ទុអប្បបរិមា១៥ លើទម្រង់សង្កេតសាលារៀន [សូចនាករលេខ ១៥]}}{\text{ចំនួនសាលារៀនសរុបតាមស្រុកនីមួយៗ}} =$ ) | | | | | | | | |
| ១៧ | ចំនួនថ្នាក់រៀនសរុបដែលបានសង្កេត | | | | | | | | |
| ១៨ | ចំនួននៃការសង្កេតសរុបដែលមានពិន្ទុអប្បបរិមា ៧ ( សូចនាករគុណភាពរកឃើញ ៧០% ) | | | | | | | | |
| ១៩ | ភាគរយថ្នាក់រៀននៃសូចនាករគុណភាពដែលរកឃើញ ៧០%<br>( គណនា ៖ $\frac{\text{ចំនួននៃការសង្កេតសរុបដែលមានពិន្ទុអប្បបរិមា ៧ [សូចនាករ ១៨]×១០០}}{\text{ចំនួនថ្នាក់រៀនសរុបដែលបានសង្កេត [សូចនាករលេខ ១៧]}} =$ ) | | | | | | | | |

..................ថ្ងៃទី........ខែ.............ឆ្នាំ២០១...

*បានឃើញ និងឯកភាព* *អ្នកធ្វើតារាង*